# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI00146**

## សម្ភាសន៍ជាមួយឈ្មោះ ឆាយ ផាន ភេទស្រី អាយុ៥៥ឆ្នាំ
## តួនាទីជំនាន់ខ្មែរក្រហម ៖ "ប្រធានកងតូច (ចល័តប្រចាំទំនប់ត្រពាំងថ្ម)"
## រស់នៅភូមិជើងវត្ត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ សោម ប៊ុនថន និង ចាន ប្រុញ
## ០១:០៧:៣២
## ៣៤ទំព័រ

ប៊ុនថន ៖ ជាដំបូងស ខ្ញុំចង់សួរឈ្មោះអ្នកមីងតើអ្នកមីងមានឈ្មោះអ្វីដែរ?

ផាន ៖ ឆាយ ផាន ។

ប៊ុនថន ៖ ឆាយ ផាន ។ អាយុប៉ុន្មានហើយមីង?

ផាន ៖ ខ្ញុំសព្វថ្ងៃ ៥៥ ហើយ ។

ប៊ុនថន ៖ ៥៥ ។ ចុះអ្នកមីងមានស្រុកកំណើតនៅភូមិឃុំអ្វីដែរ?

ផាន ៖ នៅស្រុកព្រះនេត្រព្រះនេះឯង ។ គេហៅថាភូមិជើងវត្ត នេះហ្នឹងគេហៅភូមិជើងវត្ត ។

ប៊ុនថន ៖ ឃុំព្រះនេត្រព្រះ ។

ផាន ៖ ស្រុកព្រះនេត្រព្រះ ។

ប៊ុនថន ៖ បាទ ។ ប៉ុន្តែពីមុន ស្រុកព្រះនេត្រនេះមិននៅក្នុងខេត្តបន្ទាយមានជ័យទេមីងអី? នៅខេត្តបាត់ដំបងមែនទេ?

ផាន ៖ ចា៎! នៅខេត្តបាត់ដំបង តែសព្វថ្ងៃគេហៅខេត្តបន្ទាយមានជ័យ ។

ប៊ុនថន ៖ ហើយចុះអ្នកមីងមានបងប្អូនប៉ុន្មាននាក់ដែរអ្នកមីង?

ផាន ៖ បងប្អូនខ្ញុំមានប្រាំនាក់ ។

ប៊ុនថន ៖ ស្រីប៉ុន្មានប្រុសប៉ុន្មានអ្នកមីង?

ផាន ៖ ស្រីបី ។

ប៊ុនថន ៖ ប្រុសពីរ ។

ផាន ៖ ប្រុសពីរហ្នឹងហើយ ។

ប៊ុនថន ៖ ចុះអ្នកមីងជាកូនទីប៉ុន្មានដែរអ្នកមីង?

ផាន ៖ ខ្ញុំកូនបង រៀមច្បងគេ ។

ប៊ុនថន ៖ ចុះបងប្អូនទាំងអស់នៅរស់ទាំងអស់ទេ អ្នកមីង?

ផាន ៖ ចា៎! នៅរស់ ។

ប៊ុនថន ៖ នៅឯណាទៅ សព្វថ្ងៃហ្នឹង?

ផាន ៖ នេះ នៅឯនេះ សព្វថ្ងៃហ្នឹងគេទៅបាងកកទៅអីអស់ហើយ ។

ប៊ុនថន ៖ ទៅប៉ុន្មាននាក់?

ផាន ៖ ទៅបាងកកនោះ ទៅតែម្នាក់ទេ ហើយបងប្អូនស្រីៗនៅនេះឯង មានតែអាប្អូនប្រុសខ្ញុំ អាបន្ទាប់ខ្ញុំហ្នឹងទើបទៅបាងកក ។

ប៊ុនថន ៖ អ៊ីចឹងរស់នៅជុំគ្នាទាំងអស់ ។

ផាន ៖ ចា៎!

ប៊ុនថន ៖ ហើយចុះឪពុកម្តាយអ្នកមីងនោះ?

ផាន ៖ ឪពុកខ្ញុំស្លាប់ហើយ នៅតែម្តាយចាស់ ។

ប៊ុនថន ៖ គាត់ស្លាប់ឆ្នាំណា ឪពុកមីង?

ផាន ៖ ពុកខ្ញុំស្លាប់បានយូរគ្រាន់ដែរ ប្រហែលជា ៥, ៦ ឆ្នាំហើយ ។

ប៊ុនថន ៖ អ៊ី! ទើបតែស្លាប់ក្រោយនេះទេ ។

ផាន ៖ ចា៎! ក្រោយសម័យប៉ុលពតនេះទេ ដែលរដ្ឋយើងរំដោះបានហើយទើបបានគាត់ស្លាប់ ។

ប៊ុនថន ៖ បាទ! អ៊ីចឹងម្តាយអ្នកមីងរស់នៅជាមួយមីង?

ផាន ៖ អត់ទេ គាត់រស់នៅជាមួយប្អូនពៅរបស់ខ្ញុំ ។

ប៊ុនថន ៖ បាទ! ហើយចុះអ្នកមីងបានរៀនសូត្រដល់ណាដែរ?

ផាន ៖ ខ្ញុំបានរៀនថ្នាក់ទី ៩ ។

ប៊ុនថន ៖ ចុះបើគិតមកដល់សព្វថ្ងៃវិញ តើថ្នាក់ទីប៉ុន្មានទៅ?

ផាន ៖ មិនដឹងជាស្មើទីប៉ុន្មានទេ ។

ប៊ុនថន ៖ ទី១២ ទី១១ ទី១០ ទី៩ អ៊ីចឹងស្មើថ្នាក់ទី ៨ ឥឡូវ ។

ផាន ៖ ចា៎!

ប៊ុនថន ៖ អ៊ីចឹងមានរៀននៅសាលាណាដែរ?

ផាន ៖ ខ្ញុំរៀននៅសាលាព្រះនេត្រព្រះនេះឯង ។

ប៊ុនថន ៖ ហើយចុះមីងឈប់ឆ្នាំប៉ុន្មានដែរទៅមីង?

ផាន ៖ យូរហើយ ខ្ញុំមិនសូវជាចាំទេ ។

ប៊ុនថន ៖ មុនសម័យមុនលន់នល់ ឬមួយក៏ក្រោយហ្នឹង?

ផាន ៖ មុនលន់នល់ ។

ប៊ុនថន ៖ មុនលន់នល់ទៀត ។ អ៊ីចឹងប្រហែលជាឆ្នាំ ៦០ ជាងហើយ អ្នកមីង ។

ផាន ៖ ចាំ ។

ប៊ុនថនៈ អ្នកមីងកាលណោះឈប់ហើយអ្នកមីងធ្វើអីវិញទៅ?

ផាន ៖ ខ្ញុំឈប់ហើយអត់មានទៅធ្វើអីទេ មានតែនៅផ្ទះហ្នឹងហើយ អត់បានទៅណាទេ ។

ប៊ុនថន ៖ បាទ! អ៊ីចឹងមីងនៅផ្ទះជាមួយឪពុកម្ដាយរបស់អ្នកមីងរហូត?

ផាន ៖ ចាំ!

ប៊ុនថន ៖ ហើយចុះឪពុកម្ដាយរបស់មីងគាត់ធ្វើអីដែរ?

ផាន ៖ គាត់ធ្វើស្រែ អត់បានធ្វើអីទេ ។

ប៊ុនថន ៖ បាទ! អ៊ីចឹងមីងនៅជួយមើលការងារស្រែចម្ការអីទៅមីង?

ផាន ៖ ចាំ!

ប៊ុនថន ៖ ហើយចុះក្រោយមកទៀត ?

ផាន ៖ ក្រោយមកទៀត ខ្ញុំអត់មានបានទៅធ្វើអីនោះទេ ។ នៅជាមួយម៉ែឪហ្នឹង ។

ប៊ុនថន ៖ នៅរហូត ។ បាទ! ហើយចុះកាលលន់នល់ធ្វើរដ្ឋប្រហារហើយ តើមីង ដូចថានៅក្នុងភូមិនេះមានខាងខ្មែរក្រហម មានចលនាតស៊ូអីគេចូលមកទេ?

ផាន ៖ អត់ទេ អត់មានចូលដល់មកទេ ។ រហូតទាល់តែនេះ ដូចថាសម័យ ដល់ប៉ុលពតមកទើបមានសន្តិភាពតែម្ដង ។

ប៊ុនថន ៖ សម័យលន់នល់ហ្នឹងឆ្នាំ ៧០ ណាអ្នកមីង ។

ផាន ៖ ចាំ! ឆ្នាំ ៧០ ហ្នឹង ។

ប៊ុនថន ៖ ឆ្នាំ ៧០ហ្នឹង ខាងនេះខាងលន់នល់ទេ?

ផាន ៖ ហ្នឹងហើយ ខាងលន់នល់ អត់មានខាងខ្មែរក្រហមអីចូលទេ ។ អត់ចូលបានទេ ។ ដល់តែចូលបានហ្នឹងទើបសន្តិភាពតែម្ដង ។

ប៊ុនថន ៖ ឆ្នាំ ៧៥ ហ្នឹង ។

ផាន ៖ ចាំ!

ប៊ុនថន ៖ អ៊ីចឹងប្រជាជនអីនៅរស់នៅធម្មតាទេ?

ផាន ៖ ចាំ!

ប៊ុនថន ៖ ចុះពេល ៧៥ ហ្នឹងពេលចូលភ្នាមហ្នឹង ភូមិហ្នឹងមានអ្វីប្រែប្រួលទេ? មានរៀបចំអីឡើងវិញទេអ្នកមីង?

ផាន ៖ ពេលចូលភ្នាមហ្នឹងមានជម្លៀសខ្ញុំចេញពីភូមិនេះ ។ ភូមិខ្ញុំធ្លាប់នៅទីលំនៅនេះអី គេអត់ឲ្យនៅទេ គេឲ្យចេញទៅនៅស្រែសហើយបានជាគេឲ្យខ្ញុំទៅរស់នៅខាងតាពេន ភូមិជើងវត្តហ្នឹងគេឲ្យទៅនៅតាពេនទាំងអស់ ។

ប៊ុនថន ៖ នៅតាប៉ែន តាប៉ែនហ្នឹងនៅឃុំណា?

ផាន ៖ នៅនេះឯង ភូមិជាប់គ្នា បណ្ដើរគ្នាហ្នឹងហើយ ពីជើងវត្ត ភូមិកណ្ដាល ប៉ុស្ដិ៍ចាស់ ប៉ោយសំរោង ប៉ោយព្រីង ប៉ោយតាប៉ែន ។ ឲ្យទៅនៅឲ្យឆ្ងាយពីភូមិនេះ ភូមិនេះខ្ញុំអត់បានចូលវិញទេ គេជម្លៀសចេញ ។

ប៊ុនថន ៖ អីចឹង វត្តចាស់ហ្នឹងទាំងអស់តែម្ដង ច្រើនគ្រួសារទេអ្នកមីង?

ផាន ៖ ច្រើនដែរ ។

ប៊ុនថន ៖ ប៉ុន្មានទៅអ្នកមីង?

ផាន ៖ ជម្លៀសរួមតាំងពីប៉ោយក្លឿង ឯណាៗ ច្របល់គ្នាទាំងអស់ ។

ប៊ុនថន ៖ ជម្លៀសប្រហែលប៉ុន្មានភូមិដែរអ្នកមីង?

ផាន ៖ ច្រើន ។

ប្រុញ ៖ ទាំងអស់គ្នាក្នុងភូមិហ្នឹងតែម្ដង?

ផាន ៖ ចា៎! គេឲ្យចេញទាំងអស់ ។

ប៊ុនថន ៖ អីចឹងគេចូលទៅដល់តែមួយភូមិហ្នឹងទេ?

ផាន ៖ អត់ទេ ។ ដូចថាភូមិចក្រី ភូមិកណ្ដាល ប៉ុស្ដិ៍ចាស់ ប៉ោយសំរោង ប៉ោយព្រីង ហ្នឹងគឺមានលាយគ្នា ។

ប្រុញ ៖ ចុះអ្នកមីងមានដឹងថាមូលហេតុអ្វីបានជាគេជម្លៀសដែរឬទេ?

ផាន ៖ ទេ ខ្ញុំអត់ដឹងទេ គេឲ្យចេញក៏ចេញតាមគេទៅ អត់មានបានយកអីទៅនោះទេ របស់របរទ្រព្យសម្បត្តិអីហ្នឹងក៏អត់បានយកទៅដែរ ។ មានតែរទេះគោហ្នឹង ។ គេខ្លះអត់ទៅ គេក៏រែកទៅណា៎ ។ ខ្ញុំមានរទេះគោហ្នឹងក៏ដាក់អីវ៉ាន់ទៅ អត់មានយកអីទៅធំដុំទេ មានតែអង្ករមិនចង់នឹងគ្រប់ដង ។ ហើយខោអាវស្លៀកពាក់តែបន្តិចបន្តួច ។ ហើយអីវ៉ាន់ដូចថាចានឆ្នាំងរបស់ល្អៗអីហ្នឹងទុកចោលទាំងអស់ ព្រោះស្មានតែគេឲ្យមកវិញ ។ គេអត់ឲ្យមកវិញក៏ចោលទៅ ។

ប្រុញ ៖ កាលហ្នឹងគេមានប្រាប់ថាគេជម្លៀសយើងអីទេ?

ផាន ៖ អត់ទេ គេអត់ប្រាប់ទេ ។

ប្រុញ ៖ កាលជម្លៀសហ្នឹងគេ គេបង្ខំយើងឬមួយក៏គ្រាន់តែគេនិយាយទូទៅថាឲ្យជម្លៀសឬមួយយ៉ាងណា?

ផាន ៖ ចាំ! គេនិយាយទូទៅថាឲ្យចេញមួយរយៈហ្នឹង ហើយដល់ពេលថាមួយរយៈហ្នឹង មាននរណាគេយកអីទៅទេ ។ ស្រូវអង្ករជ្រូកមាន់ទាអីហ្នឹងអត់មានទេ បានតែម៉ាអង្ករស៊ីហ្នឹង ហើយគេមកជម្លៀសទៅ ។

ប្រុញ ៖ ពីណាគេមកជម្លៀសទៅហ្នឹង?

ផាន ៖ ពួកប៉ុលពត ។

ប្រុញ ៖ ពួកប៉ុលពត ខាងខ្មែរក្រហម?

ផាន ៖ ចាំ! ខាងខ្មែរក្រហម ។

ប៊ុនថន ៖ ខាងខ្មែរក្រហម ខាងកងទ័ពហ្នឹងអ្នកមីង?

ផាន ៖ កងទ័ពហ្នឹង គេឲ្យចេញ គេចេញទាំងអស់គ្នាហ្នឹង គ្មាននរណាបានអីទេ បានតែម៉ាស្លៀកពាក់ហ្នឹងឯង ។

ប្រុញ ៖ កាលដែលគេជម្លៀសហ្នឹងមាននរណាគេដែលគេប្រាប់ថាឲ្យជម្លៀសហ្នឹង តើមីងស្គាល់គាត់ដែរ?

ផាន ៖ ទេ ខ្ញុំអត់ស្គាល់ទេ គេថាអង្គការៗ ខ្ញុំអង្គការនឹងគេដែរទៅ មិនដឹងជាអង្គការណាទេ គេគ្រាន់តែប្រាប់ឲ្យចេញទៅ យើងមិនដឹងទេ ។

ប៊ុនថន ៖ ហើយគ្រួសារអ្នកមីងទៅទាំងអស់គ្នាទៅ ទៅភូមិអី?

ផាន ៖ ភូមិតាប៉ែន ។ ចាំ! ទៅទាំងអស់ ។

ប្រុញ ៖ ជម្លៀសហ្នឹងប្រហែលជាក្នុងខែណាឆ្នាំណា? ប្រហែលតែខែ? ឆ្នាំ៧៥ ត្រូវទេ?

ផាន ៖ ចាំ! តែមិនដឹងជាខែណា តែដឹងតែដែលពិសាខហ្នឹងទេ ខែពិសាខហ្នឹងខែ៦ ឬ ៥ ។

ប៊ុនថន ៖ ខែ ៦ ខែ ៥ ប្រហែលខែហ្នឹងមីង?

ផាន ៖ ចាំ!

ប៊ុនថន ៖ ចុះពេលចេញទៅហ្នឹងគេមានរៀបចំយ៉ាងម៉េចវិញទៅ?

ផាន ៖ គេមានរៀបចំជាក្រុមៗទៅ ហើយគេឲ្យរស់នៅតាមពួកតាមក្រុមរបស់គេ ។ គេធ្វើការក៏គេហៅតាមពួកតាមក្រុមដែរធ្វើការដែរ ។ ក្រុមរបស់ខ្ញុំក៏នៅនារីអីក៏គេហៅចេញទៅក្រៅ

ទៅជួយបោកស្មៅនឹងគេដែរ ។  ហើយដល់ពេលគេរើសកម្លាំងធ្វើទំនប់ធ្វើអីហ្នឹងក៏គេរើស ទៅៗ គេមានតម្រូវមួយឃុំឲ្យបានប៉ុន្មានអីចឹង ក៏ទៅៗ ទៅៗហ្នឹងទៅហើយមិនបានមក ចូលភូមិវិញទេ ។

ប៊ុនថន : ចុះអ្នកមីងចូលទៅហ្នឹងចូលកងនារីឬក៏កងកុមារ អ្នកមីង?

ផាន : ខ្ញុំនៅកងនារី ។

ប៊ុនថន : បាទ! ព្រោះអ្នកមីងអាយុរៀងគ្រាន់ដែរ ។

ផាន : ខ្ញុំអាយុច្រើនដែរ ខ្ញុំនៅកងនារី ។

ប៊ុនថន : កាលហ្នឹងនៅជាមួយនរណា អ្នកមីង?

ផាន : កាលហ្នឹងនៅជាមួយអ៊ំឈ្មោះ អ៊ំវ៉ាល ។

ប៊ុនថន : វ៉ាលហ្នឹងប្រុសឬអ្នកមីង?

ផាន : ប្រុស ។

ប៊ុនថន : ចុះគាត់អ្នកស្រុកណាដែរ?

ផាន : គាត់ហ្នឹងអ្នកស្រុកណាទេ ខ្ញុំអត់ស្គាល់ទេ គាត់ហ្នឹងដូចជាអ្នកស្រុកសៀមរាប ។ ពីដើម គាត់ហ្នឹងមេរបស់គេ ។ គាត់ក្ដាប់រួមទៅ ។

ប្រុញ : គាត់ក្ដាប់ម៉ានៅភូមិប៉ែនហ្នឹងតែម្ដង?

ផាន : ទេ គាត់ក្ដាប់តែមួយព្រួញចល័តហ្នឹងទាំងអស់ ។

ប៊ុនថន : កាលហ្នឹងប៉ុន្មាននាក់ទៅម៉ាកងហ្នឹង?

ផាន : អូ! ច្រើនណាស់ ។

ប៊ុនថន : ប្រហែលជាប៉ុន្មានទៅ?

ផាន : ច្រើនដែរហ្នឹងណា ។ ១៤ ១៥ កងហ្នឹង ។ កងកុមារ កងនារី កងវ៉ៃកណ្ដាលមានតាម ថ្នាក់របស់វា ។

ប៊ុនថន : មួយកងមានប៉ុន្មាននាក់ទៅ?

ផាន : មួយកងធំមានមួយរយ ។ មួយកងតូចមាន ៣០ ។

ប៊ុនថន : អីចឹង ទាំងកងតូចកងធំហ្នឹង វ៉ាលហ្នឹងគាត់អ្នកគ្រប់គ្រង ។

ផាន : ចា៎! គាត់អ្នកគ្រប់គ្រងទាំងអស់ ។

ប៊ុនថន : ប្រហែលសរុបទៅប៉ុន្មាននាក់មួយកងទាំងអស់ហ្នឹង?

ផាន ៖ ច្រើនដែរ ។ ប្រហែលប្អូនប្រាំរយនាក់ហ្នឹង ។ គ្មានដឹងពីណាមួយទេ គេបញ្ចូលគ្នាទាំងអស់មកលើកទំនប់ហ្នឹង ដូចតាអានត្រពាំងថ្មហ្នឹងអីចឹង មកយកគ្រប់ភូមិគ្រប់ស្រុកគ្រប់ខេត្តមកបញ្ចូលលើកតែម្តង ។

ប៊ុនថន ៖ ចូលដំបូងហ្នឹងមីងនៅជាមួយតាវ៉ាល?

ផាន ៖ ខ្ញុំនៅកងតូច ។ កូនកងគេរែកតាមធម្មតា ។

ប៊ុនថន ៖ ចុះនរណាប្រធានកងតូចមីង?

ផាន ៖ ប្រធានកងតូចហ្នឹងគឺអ្នកស្រុកស្ទឹងកំបុត ។

ប៊ុនថន ៖ គាត់ឈ្មោះអីទៅអ្នកមីង?

ផាន ៖ គាត់ឈ្មោះរឿន ។

ប៊ុនថន ៖ គាត់នៅរស់ទេសព្វថ្ងៃហ្នឹង?

ផាន ៖ នៅរស់តើ ។

ប៊ុនថន ៖ នៅឯណាដែរសព្វថ្ងៃហ្នឹង?

ផាន ៖ នៅភូមិកណ្តាល ប៉ុស្តិ៍ចាស់ ។

ប៊ុនថន ៖ ឈ្មោះរឿនហ្នឹង?

ផាន ៖ ចាំ! គេហៅក្រៅអីចឹងគឺរឿន តែដល់គេហៅក្នុងបញ្ជីហ្នឹងគឺនារីម៉ុ ។

ប៊ុនថន ៖ នារីម៉ុ ។ គាត់ហ្នឹងគ្រប់គ្រងបានប៉ុន្មាននាក់?

ផាន ៖ គាត់ហ្នឹងក្តាប់តែកងតូចទេ ។

ប៊ុនថន ៖ កងតូចហ្នឹង៣០នាក់មីង?

ផាន ៖ ចាំ! កងធំមួយរយ ។

ប៊ុនថន ៖ អីចឹងមួយកងមីងហ្នឹងសុទ្ធតែអ្នកនៅក្នុងភូមិជាមួយគ្នា?

ផាន ៖ អត់ទេ ច្របល់លាយគ្នា ។

ប៊ុនថន ៖ មកពីភូមិណាខ្លះ?

ផាន ៖ អូ! ច្រើនណាស់ ។ មកពីខាងខាងសំពៅលូន អីឯណាជុំគ្នាច្រើនណាស់ ។

ប៊ុនថន ៖ អូ!មកពីខាងបាត់ដំបងទៀតអីមកដែរ?

ផាន ៖ ចាំ! ច្រើនណាស់លាយគ្នា ។

ប្រុញ ៖ អត់ទោសអ្នកមីង ចង់សួរមីងទាក់ទងនឹងម្នាក់ឈ្មោះវ៉ាលហ្នឹង តើកាលហ្នឹងពេលដែលអ្នកមីងទៅហ្នឹងគឺទៅហ្នឹងជាមួយគាត់តែម្តងឬ?

ផាន ៖ ទៅនៅជាមួយកងតូច តែគាត់ហ្នឹងខាងក្តាប់រួម គាត់ខាងដោះស្រាយខាងម្ហូបខាងអាហារ ខាងរួមទាំងអស់ បើនរណាឈឺស្កាត់អី គាត់នេះហើយហៅពេទ្យគេចេះមើល ។

ប្រុញ៖ ពេលហ្នឹងពេលគេបម្រុងធ្វើទំនប់ធ្វើអីហ្នឹង?

ផាន ៖ ចាំ! គាត់អ្នកមើលផ្តល់អាហារ ផ្តល់អីហ្នឹង ហើយដល់នរណាគេឈឺអីគាត់ហៅឲ្យពេទ្យមក មើលព្យាបាលឲ្យ ។

ប្រុញ ៖ ចុះមាននរណាធ្វើការជាមួយវ៉ាលហ្នឹងទៀតប្អូយ៉ាងម៉េចដែរ? ជួយធ្វើការឲ្យហ្នឹង?

ផាន ៖ យូរហើយខ្ញុំភ្លេចឈ្មោះអស់ហើយ ។ ចាស់ៗគ្នាគាត់ហ្នឹង ។ ខ្ញុំភ្លេចគាត់ហើយ ។

ប៊ុនថន ៖ បាទ!ខ្ញុំសួរបន្ត ។ ចុះអ្នកមីងមុនដំបូងគេបែងចែកការងារយ៉ាងម៉េចទៅអ្នកមីង? ពេល គេបែងចែកកងហើយ?

ផាន ៖ ពេលគេបែងចែកកងហើយហ្នឹងគេឲ្យនៅតាមក្រុម ។

ប៊ុនថន ៖ មួយក្រុម?

ផាន ៖ មួយក្រុមហ្នឹងមានដប់នាក់ទទួលការខុសត្រូវនរណាឈឺអីទៅរាយការណ៍ឲ្យប្រធានកង ។ នរណាធ្វើការអត់រួចអីទៅរាយការណ៍ឲ្យគេ ។ ឈឺក៏ដោយមិនឈឺក៏ដោយទៅធ្វើការទៅ ដូចក្រុមខ្ញុំអីចឹង អ្នកជាទៅគេធ្វើការទៅ អ្នកជាទៅគេនៅកន្លែងទៅ ។

ប៊ុនថន ៖ កាលហ្នឹងធ្វើការនៅកន្លែងណាខ្លះដំបូងហ្នឹង?

ផាន ៖ ដំបូងហ្នឹងនៅទំនប់កំពោរស្រែសនៅជិតនេះឯង រន្ទះបាញ់ ។

ប៊ុនថន ៖ កំពោរស្រែស នៅជិតនេះ ។

ផាន ៖ ចាំ! នៅជិតនេះឯង ។

ប្រុញ ៖ ធ្វើនៅហ្នឹងហើយបានទៅធ្វើនៅត្រពាំងថ្ម?

ផាន ៖ ចាំ!

ប៊ុនថន ៖ ដំបូងហ្នឹងមានហូបតាមក្រុមប្អូទៅ?

ផាន ៖ តាមក្រុម ។

ប៊ុនថន ៖ មួយក្រុមដប់នាក់អីចឹងទៅ?

ផាន ៖ ចាំ! ដួសសម្លមកហូបជុំគ្នាទៅ ។

ប៊ុនថន ៖ មួយថ្ងៃលើកប៉ុន្មាននៅនេះ គេដាក់កំណត់ឲ្យ?

ផាន ៖ គេកំណត់ឲ្យម៉ៃហ្នឹងគេឲ្យបីម៉ែត្រគីបកន្លះ ។

ប្រុញ ៖ ក្នុងម្នាក់?

ផាន :	ចាំ!

ប៊ុនថន :	អត់គិត ក្មេងចាស់អីទេ ដឹងតែម្នាក់បីម៉ែត្រគីបកន្ទះតែម្តង?

ផាន :	ចាំ! អត់គិតសោះ ។ បើនរណាអាចរែកក្នុងបីម៉ែត្រគីបកន្ទះនេះរួច ពេលមុនដំបូងហ្នឹង អីចឹងគេឲ្យធ្វើរួមជុំគ្នា តែដល់ពេលគេចម្រាញ់យកមកដាក់កងពិសេស ទើបគេវាស់ដាក់ម៉ែត្រគីប ។

ប្រុញ :	កាលចែកហ្នឹងនៅក្នុងឆ្នាំប៉ុន្មានដែរអ្នកមីង? ពេលដែលយើងមានចែកថាបីម៉ែត្រកន្ទះគីប កន្ទះហ្នឹង ចាប់ពីឆ្នាំណាមក?

ផាន :	នៅក្នុងពេលដែលគេចាប់ផ្ដើមលើកទំនប់នេះឯង ។

ប៊ុនថន :	អីចឹងដំបូងទំនប់នៅខាងនេះដំបូងគឺលើករួមទេ?

ផាន :	លើករួមបានមួយកំណាត់ទៅ ដល់ពេលអាមកដឹកស្រែសយើងនេះបានគេរៀបរើស ចម្រាញ់ បើនរណាធ្វើការខ្លាំងសកម្មជាងគេនោះគេលើកដាក់កងពិសេស ។

ប៊ុនថន :	ដាក់ចូលកងពិសេស ។ ចុះក្រុមមីងហ្នឹងគេរើសប៉ុន្មាននាក់ទៅ?

ផាន :	បាន ១០ នាក់ ១០នាក់ហ្នឹងបានម៉ាកងពិសេស ។

ប៊ុនថន :	ទាំង១០នាក់ហ្នឹងទៅទាំងអស់?

ផាន :	ជងពិសេស ១០ នាក់ហ្នឹងឯង ។ ១០ នាក់ហ្នឹង ហើយក្នុងកងពិសេសនេះ គេយកមក នៅក្បែរគ្នា គ្រាន់ទទួលការខុសត្រូវ ។ ក្នុងមួយអាទិត្យអីចឹង គេចាក់ថ្នាំឲ្យ ថ្នាំកម្លាំងថ្នាំ អីហ្នឹងដើម្បីឲ្យចេះធ្វើការខ្លាំង ។ គេមើលបានជិតដល់ហ្នឹង ខ្លាចឈឺអីហ្នឹង ។

ប៊ុនថន :	នៅជិតតាវ៉ាលហ្នឹង?

ផាន :	នៅជិតគាត់ ។ គាត់មើលជម្ងឺហ្នឹង ថាអ្នកធ្វើការកងពិសេសហ្នឹងស៊ីចុកហ្នឹងវាយ៉ាងម៉េច យ៉ាងម៉េច គេបំប៉នយើងដែរ ។

ប៊ុនថន :	កាលហ្នឹងគាត់នៅឯណាកន្លែងគាត់ធ្វើការហ្នឹង?

ផាន :	ចាំ! កន្លែងគាត់ផ្ទះគាត់នេះប្រពន្ធគាត់ផ្ទះនៅឯជប់ ។

ប៊ុនថន :	ជប់ហ្នឹងនៅតាមផ្លូវជាតិហ្នឹង?

ផាន :	ចាំ! តាមផ្លូវជាតិហ្នឹងនៅទល់មុខសាលាស្រុក ផ្ទះគាត់ហ្នឹងឯង ។

ប្រុញ :	ថ្នាំគាត់ហ្នឹងចាក់ទៅមានកម្លាំងតែម្តង ពេលគាត់ចាក់ទៅ?

ផាន :	ចាំ! ចាក់ថ្នាំឲ្យ ដូចថាថ្នាំកម្លាំងអីចឹង ដូចថារៀងស គាត់ថាឲ្យចាក់មួយអាទិត្យឲ្យចាក់ម្តង

ប្រុញ :	អាហ្នឹងមិនមែនយើងឈឺឯណា គាត់ចាក់ឲ្យតែម្តង?

ផាន ៖ ចាំ! អត់ឈឺទេ គាត់ចាក់បំបនកម្លាំង ឲ្យយើងមានកម្លាំងដូចថាយើងធ្វើការខ្លាំង ។

ប្រុញ ៖ កាលហ្នឹងកងពិសេសមានច្រើនកងដែររឺទេ?

ផាន ៖ មានតែមួយកងទេ ។

ប្រុញ៖ មួយកងដប់នាក់ ។

ផាន ៖ ចាំ!

ប៊ុនថន ៖ អាហ្នឹងរើសចេញពីណាខ្លះ?

ផាន ៖ រើសចេញ កាលនោះ បើខ្ញុំនិយាយទៅកុំឲ្យប្រកាន់ខ្ញុំ ដូចថាគេហៅថាប្រជាជនថ្មី អ្នកមកពីឆ្ងាយៗគេហៅថាប្រជាជនថ្មី បើគាត់ធ្វើការល្អ គាត់សកម្មនឹងការងារ គេក៏រើសបញ្ចូល ឈ្មោះហ្នឹង ខ្ញុំចាំបានឈ្មោះបងរីហ្នឹងម្នាក់ បងប៊ុនហ្នឹងម្នាក់ បងរីណាហ្នឹងម្នាក់ ។

ប៊ុនថន ៖ អាហ្នឹងសុទ្ធតែអ្នកថ្មី?

ផាន ៖ ចាំ ។ គាត់និយាយប្រាប់ខ្ញុំ គាត់សុំកុំឲ្យខ្ញុំនិយាយ គាត់ថាគាត់ហ្នឹងជានិស្សិត គាត់លាក់ប្រវត្តិរូបរបស់គាត់ គាត់សុំតែម៉ារស់ៗណាំ ។

ប្រុញ ៖ គាត់ឈ្មោះអីខ្លះ?

ផាន ៖ ឈ្មោះបងរី បងប៊ុន និងរីណា ។

ប្រុញ ៖ គាត់ហ្នឹងមកពីណា?ភ្នំពេញ?

ផាន ៖ ចាំ! មកពីភ្នំពេញ ។

ប្រុញ៖ គាត់ហ្នឹងធ្វើការល្អ?

ផាន ៖ ចាំ! ធ្វើការល្អ ។

ប៊ុនថន ៖ ហើយចុះសព្វថ្ងៃហ្នឹងគាត់នៅរស់ទេ?

ផាន ៖ ទេ សព្វថ្ងៃនេះខ្ញុំមិនដឹងទេ ដូចថានេះទៅ ដល់ស្រុកសុខទៅ គាត់ក៏ទៅតាមស្រុកតាមស្រែគាត់អស់ទៅ ។

ប៊ុនថន ៖ ចុះក្រៅពីគាត់មីងមាននៅចាំឈ្មោះទៀតដែរឬទេ?

ផាន ៖ នេះ ទាស់តែគេទៅថៃអស់ហើយ ។

ប៊ុនថន ៖ ឈ្មោះអីខ្លះ អ្នកមីង?

ផាន ៖ ឈ្មោះ លឿង ហ្នឹងមួយ ។ គាត់ឈ្មោះ ដា ។

ប៊ុនថន ៖ ដា?

ផាន ៖ ចាំ! គាត់ទៅនៅឆ្ងាយៗហើយ ទៅថៃហើយ ។

ប្រុញ ៖ គាត់ហ្នឹងត្រូវគេរើសចូលកងពិសេសដែរ?

ផាន ៖ ចា៎! គេរើសចូលកងពិសេស ។

ប៊ុនថន ៖ កាលហ្នឹង ប្រហែលជាឆ្នាំប៉ុន្មានពេលមីងចូលកងពិសេស ដូរពីនេះទៅ ដូរពីលើកទំនប់ជិតនេះ?

ផាន ៖ ចា៎! នៅឆ្នាំប៉ុន្មានទេ ។ ខ្ញុំភ្លេចអស់ហើយ ។ ដល់ពេលយូរទៅក៏ខ្ញុំមិនសូវចាំដែរ ។

ប្រុញ ៖ ចុះដល់ពេលទៅធ្វើនៅនេះយូរដែរទេ អ្នកមីង?

ផាន ៖ ធ្វើនៅនេះយូរដែរ ។ ដល់ចប់ទៅ ។

ប៊ុនថន ៖ រយៈប៉ុន្មានពេលធ្វើនៅនេះ ប៉ុន្មានខែអ្នកមីង?

ផាន ៖ យូរដែរ ជិតម៉ាឆ្នាំ ។

ប្រុញ ៖ ជម្រៀសពីនេះទៅ ទៅធ្វើការនៅនោះតែម្ដង?

ប៊ុនថន៖ អ៊ីចឹង ៧៦ ហ្នឹង មីងបានចូលកងពិសេសហើយ? បាទ! នៅនេះបានមួយឆ្នាំ បាទ! ឆ្នាំ៧៥ ហើយ ៧៦ មីងចូលកងពិសេស ។ អ៊ីចឹង អ្នកមីងនៅជាមួយគាត់ហ្នឹងយូរដែរទេ? នៅជាមួយតាវ៉ាលហ្នឹង?

ផាន ៖ នៅទំនប់ស្រែសនេះហ្នឹង នៅម៉ាចប់តែម្ដង ។ ហើយគាត់នាំទៅនៅឯណោះទៀត ។ អាង ត្រពាំងថ្មទៀត ។

ប៊ុនថន ៖ អ៊ីចឹងមីងចេញពីនេះ មីងទៅត្រពាំងថ្មតែម្ដង ។

ប្រុញ ៖ អ៊ីចឹង តាវ៉ាលហ្នឹងគ្រប់គ្រងតាំងពីនេះទៅ?

ផាន ៖ ចា៎! ហ្នឹងចប់ទៅដល់ស្ពានស្រែងទៀត ។ គាត់គ្រប់គ្រងទាំងអស់ ។

ប៊ុនថន ៖ កងចល័តគាត់គ្រប់គ្រង?

ផាន ៖ ចា៎! កងចល័តគាត់គ្រប់គ្រងទាំងអស់ ។ គាត់នាំធ្វើទំនប់ហ្នឹងរួច ទៅស្ពានស្រែងនោះទៀត ។ ទំនប់អូររំចេកទៀត គាត់នាំទាំងអស់ ។

ប្រុញ ៖ ទំនប់ត្រពាំងថ្មហ្នឹងគេធ្វើហើយឆ្នាំណាដែរ?

ផាន ៖ ខ្ញុំដូចជាមិនចាំដែរ ដល់ពេលសួរអ៊ីចឹងទៅ ខ្ញុំអត់ចាំទេ ។

ប៊ុនថន ៖ បាទ! អ្នកមីងកាលហ្នឹងគេហៅថាកងចល័តអីដែរទៅ ទាំងអស់ហ្នឹង?

ផាន ៖ គេហៅ កាលហ្នឹង ព្កតែគេហៅថាកងចល័តៗ នោះឯង ។

ប៊ុនថន ៖ ដូចថាមានកងចល័តភូមិ ចល័តឃុំ?

ផាន ៖ មានៗ ។ ចល័តភូមិផ្សេង ចល័តឃុំផ្សេង ភូមិខ្ញុំចល័តដូចថាចល័តតំបន់ ។

ប៊ុនថន : បាទ! មីងចល័តតំបន់?

ផាន : ចាំ! ខ្ញុំចល័តតំបន់ៗ មុនដំបូងទៅពីភូមិ ដល់ពេលគេរើសចូលទៅ ដល់ហ្នឹងជាប់រហូតតាំងពីប៉ុន្មានបីឆ្នាំនេះហ្នឹង ខ្ញុំវិលរហូតមិនដែលបានមកភូមិទេ គ្រាន់តែសុំគេមកលេងម្ដងៗនេះឯង ទល់តែចប់ចុងចប់ដើម ។

ប៊ុនថន : កាលចល័តតំបន់ប្រាំហ្នឹង អ្នកមីង?

ផាន : ចាំ!ៗ! ចល័តតំបន់ប្រាំ ។

ប៊ុនថន : បាទ! កាលហ្នឹងមីងមាននៅចាំ អឺ មេឃុំឬគណៈស្រុកអីទេមីង?

ផាន : ខ្ញុំអត់ចាំទេ ខ្ញុំអត់ស្គាល់ទេ ។

ប៊ុនថន : បាទ!

ផាន : ខ្ញុំភ្លេចអស់ហើយ ។

ប៊ុនថន : អ៊ីចឹង មីងស្គាល់តែតាវ៉ាល គាត់ខាងចល័តតំបន់?

ផាន : ចាំ! គាត់ហ្នឹងក្ដាប់រួម ។ ស្គាល់តែគាត់នោះឯង នៅតំបន់ប្រាំហ្នឹង ។ ផុតពីនេះទៀតទៅខ្ញុំក៏ភ្លេចហើយ ។

ប៊ុនថន : បាទ!

ផាន : សព្វថ្ងៃហ្នឹង អ្នកដែលធ្លាប់នៅចល័តជាមួយគ្នាហ្នឹងក៏ភ្លេចឈ្មោះគេអស់ហើយ ស្គាល់តែមុខៗនោះឯង ។

ប៊ុនថន : បាទ! យូរឆ្នាំហើយ ។

ផាន : ចាំ! យូរហើយ ។ ដូចថាភ្លេចភ្លាំងអស់ហើយ ចាស់ហើយ ក៏ខ្ញុំភ្លេចភ្លាំងអស់ហើយ ។

ប្រុញ : មុនដំបូងធ្វើនៅទំនប់តាស្រែសហ្នឹង ហើយប្ដូរទៅត្រពាំងថ្ម ត្រពាំងថ្មហើយទៅឯណាទៀត?

ផាន : ទៅស្ពានស្រែង ។

ប្រុញ : ស្ពានស្រែង?

ផាន : ចាំ!

ប្រុញ : តែបីហ្នឹងទេ? មានទៅឯណាទៀតទេ?

ផាន : ទេ មុនដំបូងហ្នឹងនៅរែកនៅឯនេះរួច ទៅដល់ត្រពាំងថ្ម រួចទៅធ្វើដូចគេហៅថាធ្វើចារគោកទាប ទំនប់គោរំចេក នៅទំនប់អូររំចេក ផ្លូវភ្នំស្រុក ។ អូររំចេករួច

ក៏ទៅចារគោគទាប ចាប់អាហ្នឹងហើយទៅ ទើបបានគេហៅឡើងទៅទំនប់ត្រពាំងថ្ម ។ ត្រពាំងថ្មរួចហើយ ក៏ ឡើងទៅស្ពានស្រែង ហើយក៏ចប់បណ្តោយ ។

ប៊ុនថន : ចុងក្រោយនៅស្ពានស្រែង?

ផាន : ចាំ! នៅស្ពានស្រែង ខ្ញុំរែកដី ។ ដូចថារែកអី យើងជួយគ្នា ដូចថាពីតំបន់ខាងនោះ គេហៅថាខាងសៀមរាបគេហៅថាតំបន់អីទេ មិនដឹងជាតំបន់បីឬតំបន់អីទេ គេរែកជួយគ្នា ។

ប៊ុនថន : អ៊ីចឹងអ្នកមីងចង់សួរថា ពេលដែលអ្នកមីងទៅនៅជាមួយគាត់ហ្នឹងបានយូរដែរទេ? នៅកងពិសេសហ្នឹងនៅដប់នេះ? ពេលគេដកទៅហ្នឹង?

ផាន : គេដកទៅ តែដល់ពេលនេះទៅគេរំលាយរបស់ខ្ញុំទៅ ចប់អានេះទៅគេរំលាយកងពិសេសនេះ គេឲ្យទៅកាន់កូនកង ធ្វើប្រធានកងគេ ។ ប្រធានកងក្តាប់សាមសិបនាក់នោះឯង ។ គេដកអាកងពិសេស ៗ ខ្លាំង ៗ នេះឲ្យក្តាប់ហ្នឹងណា ។

ប៊ុនថន : ក្តាប់កង ។

ផាន : ចាំ! ក្តាប់កង ។ ក្តាប់កងឲ្យនាំគេទៅធ្វើការ កងពិសេសនេះឯង អាគេរើសបានដប់នាក់នេះណា ។

ប៊ុនថន : សាមសិបនាក់?

ផាន : ចាំ!

ប្រុញ : ហើយអ៊ីចឹងទៅគ្រប់គ្រងគេសាបសិបនាក់ទៀតទៅ?

ផាន : ចាំ!

ប្រុញ : អ៊ីចឹងមានន័យថាគ្រប់គ្រងទាំងអស់បីរយនាក់ហើយទាំងដប់នាក់ហ្នឹង?

ផាន : ចាំ! គេរំលាយពីក្រុមខ្ញុំកងពិសេសទៅ គេយកទៅឲ្យក្តាប់អាកងតូច ។

ប្រុញ : បាទ! យល់! ដំបូងចេះតែឆ្ងល់ថាដប់នាក់ហ្នឹងធ្វើយ៉ាងម៉េចបានទៅ?

ប៊ុនថនៈ អ៊ីចឹង កងអ្នកមីងគ្រប់គ្រងភាគច្រើនសុទ្ធតែអ្នកនៅភូមិចាស់ៗទេ មិនមែនអ្នកថ្មីទេ?

ផាន : អ្នកថ្មីបញ្ចូលគ្នា ។

ប៊ុនថន : បាទ! អ្នកថ្មីហ្នឹងមកពីណាវិញថ អ្នកមីង?

ផាន : មកពីភ្នំពេញហ្នឹងមើលទៅ ខ្ញុំមិនស្គាល់ទេ ដូចថានេះរហូត ។

ប្រុញៈ កាលធ្វើនៅត្រពាំងថ្មគេធ្វើច្រើននាក់ទេ? គ្នាច្រើន?

ផាន : ច្រើននាក់ណាំ! មនុស្សរាប់ពាន់ ។

ប្រុញ ៖ រាប់ពាន់? ខ្ទង់ប្រហែលប៉ុន្មាននាក់ទៅ? អាចចូលដល់ម៉ឺនដែរឬទេ?

ផាន ៖ មិនដល់ម៉ឺនទេ ។

ប្រុញ ៖ អត់ដល់ទេ?

ផាន ៖ចាំ!

ប៊ុនថន ៖ អ៊ីចឹងមីង ពេលមីងក្តាប់កងតូចដឹកនាំចេញទៅធ្វើការតែម្តង?

ផាន ៖ ចាំ! ធ្វើការ ។

ប៊ុនថន ៖ កាលហ្នឹងដឹកនាំដំបូងចេញទៅធ្វើការនៅឯណាវិញ?

ផាន ៖ ធ្វើនៅអាងត្រពាំងថ្មហ្នឹងឯង ។

ប៊ុនថន ៖ អាងត្រពាំងថ្ម?

ផាន ៖ ចាំ! ទំនប់អាងត្រពាំងថ្មហ្នឹងឯង ។

ប៊ុនថន ៖ កាលហ្នឹងមីងទៅប្រហែលនៅឆ្នាំប៉ុន្មាន មីងមានចាំទេ ?

ផាន ៖ ខ្ញុំមិនបានចាំទេកាលនោះ ។

ប៊ុនថន ៖ ចុះទៅយូរដែរទេ? ពេលគេបញ្ជូនមីងទៅជាមួយតាវ៉ាលហើយហ្នឹង មីងចេញទៅតែម្តង

ផាន ៖ ចាំ!

ប៊ុនថន ៖ ហើយចុះពេលអ្នកមីងទៅដល់ដំបូងមានឃើញគេធ្វើនៅ ឬមួយគេអត់ទាន់ទេ?

ផាន ៖ អត់ទាន់ទេ ។ ទៅដល់ភ្លាមក៏គេវាស់ឲ្យវែកតែម្តងក្រុមខ្ញុំនេះ ។ វែកតែម្តង ។

ប៊ុនថន ៖ អ៊ីចឹង មីងទៅមុនគេ ឬមួយក៏?

ផាន ៖ ទៅមុនគេតែម្តង ។

ប៊ុនថន ៖ អូ! មុនគេ?

ផាន ៖ ចាំ! មុនគេ ។

ប្រុញ ៖ អ៊ីចឹងប្រហែលជាទៅធ្វើនៅឆ្នាំ ៧៦ អីមើលទៅ? បើយើងគិតទៅកន្លែងហ្នឹងប្រហែលជាធ្វើនៅឆ្នាំ ៧៦ អីហើយ ត្រពាំងថ្មហ្នឹង?

ផាន ៖ ដូចជាចុងឆ្នាំទេដឹង ។ ធ្វើយូរដែរ ។

ប៊ុនថន ៖ បាទ! ពេលមីងទៅដល់ដំបូង គេវាស់ដីឲ្យតែម្តង?

ផាន ៖ ចាំ! វាស់ដី ឲ្យវែក ។ គេឲ្យកូនកងវែក ហើយខ្ញុំក៏គេឲ្យមើល តែទៅមើលហ្នឹងមិនមែនគ្រាន់តែមើលទេណាំ ខ្ញុំក៏ត្រូវវែកដែរណាំ! ប្រធានកងក៏វែក កូនកងក៏វែក ។ វែកទាំង

អស់គ្នា មិនមែនឈរប្រុតចង្កេះចង្កុលឲ្យហ្អែងវែកហ្អែងធ្វើយ៉ាងណាអី អត់ទេ យើងវែកទាំងអស់គ្នា ។

ប្រុញ ៖ គេឲ្យវែកទាំងអស់គ្នា?

ផាន ៖ ចាំ! វែកទាំងអស់គ្នា ។ កុំថាប្រធានមិនវាស់ គឺគេវាស់ឲ្យដូចតែគ្នា ។

ប៊ុនថន ៖ នរណាអ្នកវាស់ឲ្យ? អ្នកវាស់ផ្សេង?

ផាន ៖ ចាំ!

ប៊ុនថន ៖ ពីណាវិញអ្នកមីង?

ផាន ៖ អ្នកវាស់ដី គឺផ្សេង ដូចថាប្រធាន គេកម្មាភិបាល គេហៅថាកម្មាភិបាល ប្រធានធំៗ ដែលគេវាស់ដាក់ៗឲ្យ ។

ប្រុញ ៖ មានស្គាល់ឈ្មោះគាត់ទេ?

ផាន ៖ មិនដឹងជាទៅនៅឯណាទេ ខ្ញុំមិនស្គាល់ស្រុកគេដែរ ។

ប្រុញ ៖ អីចឹង ភាគច្រើនដែលគេដឹកនាំធំៗដែលគេមកហ្នឹងមិនមែននៅក្នុងឃុំហ្នឹងទេ?

ផាន ៖ អត់មែនទេ ។

ប្រុញ ៖ សុទ្ធតែអ្នកក្រៅ?

ផាន ៖ អ្នកចម្ងាយ អ្នកក្រៅ ចាំ!

ប្រុញ ៖ ចុះអ្នកមីងដឹងថាមូលហេតុអីបានជាគេធ្វើអាត្រពាំងហ្នឹងទេ?

ផាន ៖ ខ្ញុំមិនដឹងដែរ គេថាឲ្យវែក វែកដី ធ្វើទំនប់ត្រពាំងថ្ម អាងត្រពាំងថ្ម បិតៗទៅ យើងចេះតែនាំគ្នាវែកទៅណាំ ។

ប្រុញ ៖ អត់មានប្រាប់យើងថា វែកដើម្បីធ្វើអីៗទេ?

ផាន ៖ អត់ទេ ។

ប្រុញ ៖ គ្រាន់តែប្រាប់ថាធ្វើត្រពាំងតែប៉ុនហ្នឹង?

ផាន ៖ ចាំ! ថាបិតតែទំនប់ត្រពាំងថ្ម ។

ប៊ុនថន ៖ កាលហ្នឹង មាន ដូចថាគេកំណត់ឲ្យម្នាក់វែកប៉ុន្មានទេអ្នកមីង?

ផាន ៖ បីម៉ែត្រគីបកន្លះ ។

ប៊ុនថន ៖ អាហ្នឹងអត់គិតថាប្រុសឬស្រី គឺស្មើគ្នាតែម្តង?

ផាន ៖ ស្មើគ្នាទាំងអស់ ។

ប្រុញ ៖ គេឲ្យវែកចាប់ពីអាយុប៉ុន្មានទៅ អ្នកមីង?

ផាន : អូ! កុមារក៏រែកដែរ ។ ទាស់តែកុមារគេអត់បានកំណត់ទេ ។ បើពេញរូបពេញរាង នារីពេញ ទាំងយុវជនអី គឺសុទ្ធតែមានកំណត់ គឺបីម៉ែត្រគីបកន្លះ ។

ប្រុញ : ចុះបើរែកមិនហើយធ្វើយ៉ាងម៉េចទៅ?

ផាន : រែកមិនហើយ យប់រែកទៀត ។ រែកទាំងតែហើយ ។

ប៊ុនថន : បាទ! បីម៉ែត្រគីប ដូចមីងធ្លាប់រែកអីចឹង គឺដូចជាអត់អីទេ មែនទេអ្នកមីង?

ផាន : ចាំ! អត់អីទេ ។ បង្គីរបស់ខ្ញុំធំៗណាស់ សឹងថាបីអំរែកអស់កន្លះម៉ែត្រ ។ រែកៗដល់សព្វថ្ងៃនេះ ខ្ញុំនិយាយទៅមិនថានេះទេ ខ្ញុំខ្លាចណាស់ ដូចគេថាឲ្យរែកទឹក ខ្ញុំមិនដែលរែកទេ ដល់ខ្ញុំបានរស់អីចឹងទៅ ខ្ញុំមិនដែលរែកទេ ។

ប៊ុនថន : បាទ! បាទ!

ផាន : ដូចថាវាឆ្អែតឆ្អន់អស់កាលណោះហើយ វានេះអស់ហើយស្មាហ្នឹង វាប៉ះតែដងរែកហ្នឹង វាឡើងស្រកអស់ហើយ ។

ប្រុញ : គេឲ្យរែកតាំងពីម៉ោងប៉ុន្មាន?

ផាន : ពីម៉ោងបួន ។

ប្រុញ : បួនយប់?

ផាន : ចាំ!

ប៊ុនថន : ទាំងអស់គ្នា?

ផាន : ចាំ! ទាំងអស់គ្នា ។

ប្រុញ : បួនយប់ ហើយដល់ពេលគេឈប់ម៉ោងប៉ុន្មានទៅអ្នកមីង?

ផាន : ចាំ! ម៉ោង ៩ ឡើង ដល់ធ្វើពីព្រឹកម៉ោង ១១ អីឡើងហូបបាយហើយ ។ ម៉ោង ២ អី ចុះធ្វើការវិញ ។

ប្រុញ : ដល់ពេលហើយគេភាគច្រើនឡើងម៉ោងប៉ុន្មានដែរពេលល្ងាច?

ផាន : ម៉ោង៥ ។ បើនរណាធ្វើរួចទៅ រែករួចទៅ មិនបាច់ទៅធ្វើការទៀតទេ បានសម្រាកទៅណា ។

ប្រុញ : ចុះបើសិនជាយើងរែកហើយមុនអាគេកំណត់ហ្នឹង គេយ៉ាងម៉េចដែរ?

ផាន : មានយ៉ាងម៉េចគេឲ្យយើងសម្រាកទៅ ។ បើយើងធ្វើមិនហើយ ល្ងាចឡើងយើងត្រូវទៅធ្វើទៀត ។ បើយើងថា មិនចង់ឈប់ទេ ហូបតែបាយរួចយើងចង់បានលឿនមុនគេ យើងក៏ទៅទៀតទៅណា រែកទៀតទៅណា ។

ប៊ុនថន :	បាទ! ចុះអ្នកមីងមានអ្នកវែកអត់ហើយអីទេ អ្នកមីង ដូចថាទៅកងមីងអីហ្នឹង?

ផាន :	មានដែរ ។

ប៊ុនថន :	ដល់ពេលមានអីចឹង មីងធ្វើយ៉ាងម៉េចទៅ? ដល់ពេលអត់ហើយអីចឹង?

ផាន :	បើអ្នកហើយអីចឹង បើថាស្រណោះក៏ជួយគ្នាទៅ ។

ប៊ុនថន :	ជួយគ្នា?

ផាន :	ចា៎! ជួយ បានរួចទាំងអស់គ្នា ហើយទាំងអស់គ្នាទៅណា៎ ។

ប្រុញ :	ការវែកហ្នឹងមានលើកទឹកចិត្តអីទេ ឬក៏គ្រាន់តែដាក់ការងារឲ្យយើងធ្វើហើយ ចប់មិនចប់ យើងធ្វើហើយមិនហើយ យប់ឡើងយើងត្រូវធ្វើឲ្យហើយ ឬគេមានលើកទឹកចិត្តយើង

ផាន :	អត់មានឡើងអីទេ មានតែខំឲ្យតែលើកឲ្យតែរួចហ្នឹង ។

ប៊ុនថន :	ចុះអ្នកមីងដូចថាយើងវែកហើយហ្នឹងយើងមានរាយការណ៍ទៅខាងលើដែរ?

ផាន :	ចា៎! រាយការណ៍ ។

ប៊ុនថន :	រាយការណ៍ទៅខាងណាវិញ? មីង?

ផាន :	រាយការណ៍ទៅដូចប្រធានកងធំ ។ ប្រធានកងតូចរាយការណ៍ឲ្យប្រធានកងធំ ។ ប្រធានកងធំរាយការណ៍ប្រធានវីរៈ ប្រធានវីរៈគេរាយការណ៍អ្នកលើគេទៀតទៅ ។ គេអត់មានក្តាប់រួមទេ ។

ប៊ុនថន :	បាទ! បាទ! កាលហ្នឹងប្រធានកងធំ គឺនរណាគេវិញ អ្នកមីង?

ផាន :	ប្រធានកងធំមិនមែនអ្នកស្រុកនេះទេ ។ អ្នកខាងសៀមរាប ។

ប៊ុនថន :	ឈ្មោះអីវិញអ្នកមីង?

ផាន :	ឈ្មោះម៉ិត ។

ប៊ុនថន :	ម៉ិតហ្នឹងស្រីឬក៏ប្រុស?

ផាន :	ស្រី ។

ប៊ុនថន :	ឈ្មោះមិត ឬម៉ិត?

ផាន :	ឈ្មោះម៉ិត ។ ស្រី ។

ប៊ុនថន :	ឈ្មោះមិត ។ ចុះប្រធានវីរៈមីងមាននៅចាំទេ?

ផាន :	ប្រធានវីរៈខ្ញុំមិនចាំទេ ។

ប៊ុនថន :	ប្រធានវីរៈហើយ ទើបបានទៅលើតែម្តង ។ មានប្រធានសហករណ៍ ។

ផាន :	ចា៎!

ប៊ុនថន ៖ ឈ្មោះមិតហ្នឹងឈ្មោះគាត់ពីកំណើតតែម្ដង? ឬក៏?

ផាន ៖ ខ្ញុំមិនដឹងទេ គាត់នៅឆ្ងាយដែរ ។

ប៊ុនថន ៖ គេគ្រាន់តែហៅគាត់មិតអីចឹងទៅ?

ផាន ៖ ចាំ! គាត់នៅឆ្ងាយណា នៅស្រុកមុខឈើនាង ឯណោះទេ ។ នៅមុខឈើនាង ។

ប៊ុនថន ៖ បាទ! ចុះមីងដូចថាក្រុមមីងហ្នឹងមានដែលវែកអត់ហើយទេ ដូចថាកំណត់ម្នាក់ត្រូវបីម៉ែត្រ កន្លះ ចុះបើវែកអត់ហើយទេ យើងរាយការណ៍តាមដាក់ស្ដែងទៅខាងលើ ឬមួយក៏យ៉ាងម៉េចទៅ?

ផាន ៖ រាយការណ៍ ចាំ!

ប៊ុនថន ៖ ចុះដែលធ្លាប់វែកអត់គ្រប់ចំនួនទេ?

ផាន ៖ អត់មានទេ ។ គេដាក់ប៉ុន្មាន ទោះបីជាយប់ស្មើណាក៏ដោយគឺត្រូវតែធ្វើទល់តែរួចហ្នឹងទើបបាន ។

ប៊ុនថន ៖ ចុះប្រសិនបើអត់រួចវិញ គេមានប្ដូរមេកងអីចេញទេ? ដូចថាយកទៅណែនាំអី?

ផាន ៖ អត់ទេ អត់មានទេ ។ គេគ្រាន់តែប្រជុំឲ្យយើងខិតខំធ្វើពលកម្ម កុំឲ្យយើងទំរុនស្ទក់ គេនិយាយ ហើយយើងត្រូវចេះខំបញ្ចេញពលកម្ម ត្រូវគេបំពាក់បំប៉នជិហរយើងឲ្យរឹងមាំ គេថា ។

ប៊ុនថន ៖ ខស្សាហ៍ឡើងប្រជុំដែរ?

ផាន ៖ ចាំ! គេឲ្យប្រជុំគ្នា នេះយើងខំធ្វើការទៅ ។ គេឲ្យប្រជុំ ។

ប៊ុនថន ៖ ចុះមីងខស្សាហ៍ទៅប្រជុំជាមួយប្រធានៗកងអីទេ?

ផាន ៖ ទេ ដូចគេមានហៅប្រជុំឲ្យទៅដែរ ដូចថាពេលរយៈពីរបីខែអីចឹងគេហៅទៅម្ដង ទៅរៀន ទៅរៀនឯណោះទេ គេថាទៅរៀនឯខេត្ត ទៅខេត្តអីចឹងគេយកឡានមកដាក់ទៅ ក៏ទៅ! ។

ប៊ុនថន ៖ ទៅរៀនដល់ខេត្តទេ?

ផាន ៖ ចាំ! ទៅរៀនបំពាក់បំប៉នជិហរយើង ឲ្យយើងដឹកនាំកូនកងយើងឲ្យរឹងមាំ កុំឲ្យផ្ដេកផ្ដួលទារុណស្ទក់ទៅណា គេណែនាំទៅណា ។

ប្រុញ ៖ ប៉ុន្មានខែគេហៅប្រជុំម្ដង?

ផាន ៖ ទៅប្រជុំហ្នឹងបីថ្ងៃ ។

ប៊ុនថន ៖ នៅឯណា សេរីសោភ័ណ្ឌ?

ផាន ៖ ចាំ! ជួនការទៅឯស្រុកអី ភ្នំបាក់ នោះឯង ។

ប៊ុនថន ៖ ភ្នំបាក់នៅឯណាវិញមីង?

ផាន ៖ នៅឯស្វាយយើងនេះឯង ។

ប៊ុនថន ៖ កន្លែងហ្នឹងគេហៅថាអីវិញទៅអ្នកមីង?

ផាន ៖ កន្លែងហ្នឹង ខ្ញុំក៏មិនស្គាល់ដែរ គេថាកន្លែងអង្គការៗ ហើយខ្ញុំថាអង្គការតាមតែគេទៅ មិនដឹងជាអង្គការអីទេ ។ គេគ្រាន់តែហៅទៅរៀនសូត្រអីចឹង ។

ប៊ុនថន ៖ ប៉ុនទៅដល់ហ្នឹងគេទៅច្រើនគ្នាទេអ្នកមីង?

ផាន ៖ ចា៎! ច្រើន ។

ប៊ុនថន ៖ ប្រហែលជាប៉ុន្មានទៅ?

ផាន ៖ ប្រហែលជាមួយរយនាក់ជាង ។

ប្រុញ ៖ ប្រជុំម្ដងៗដល់ទៅមួយរយនាក់ជាង?

ផាន៖ ចា៎!

ប្រុញ៖ ហើយមានគេណែនាំអីទេ?

ផាន ៖ មានមនុស្សប្រុសស្រី ប្រធានៗ គេណែនាំ គេបង្រៀនបំពាក់បំប៉នជំហររបស់យើងឲ្យដឹកនាំកូនកងឲ្យចេះធ្វើការអីទៅណា ។

ប៊ុនថន ៖ សុទ្ធតែស្គាល់គ្នាទេមីង អ្នកទៅប្រជុំហ្នឹង?

ផាន ៖ អត់បានស្គាល់ទេ ។

ប្រុញ ៖ ប្រធានអ្នកដែលគេណែនាំយើងហ្នឹង មីងអត់ស្គាល់ដែរ?

ផាន ៖ អត់ស្គាល់ទេ ។

ប៊ុនថន ៖ ចុះខាងណាទៅដែលជាអ្នកឡើងមកនិយាយ ឡើងមកខទ្វេសនាមអីហ្នឹង មកពីខាងណាវិញ? អ្នកមីង?

ផាន ៖ មិនដឹងជាខាងណាទេ ។ គេគ្រាន់តែថាអង្គការៗ អង្គការថ្នាក់លើ គេហៅថាអីចឹង ឮតែអង្គការថ្នាក់លើៗ ។

ប៊ុនថន ៖ ចុះពេលទៅប្រជុំហ្នឹង វ៉ាលហ្នឹងមានទៅប្រជុំជាមួយទេ?

ផាន ៖ អត់ទេ គាត់អត់បានទៅទេ ។

ប៊ុនថន ៖ ចុះមីងមានខស្បាហ៍ជួបគាត់ទៀតទេ? ពេលដឹកនាំកម្លាំងទៅធ្វើការហ្នឹង? គាត់ខស្បាហ៍ទៅមើលទេ?

ផាន ៖ គាត់ទៅមើលដែរ ។

ប៊ុនថន ៖ អូ! គាត់ទៅមើលដែរ ។

ផាន ៖ គាត់នៅប្រចាំការ ។ គាត់នៅកន្លែងហ្នឹងដែរជាប់ដែរ ។ គាត់មិនបានបណ្ដោយទេ ។

ប៊ុនថន ៖ បាទ! គាត់ចុះដើរមើលគ្រប់ក្រុមទៅ?

ផាន ៖ ចា៎!

ប្រុញ ៖ ចុះយើងប្រជុំហ្នឹង អំបាញ់មិញ មីងនិយាយថាភាគច្រើនគឺបីថ្ងៃ ឬមួយក៏មានលើសហ្នឹង ដូចថាយើងមានប្រជុំនៅខេត្តនៅអី?

ផាន ៖ អត់មានទេ ។ តែបីថ្ងៃៗ ។ ជួនកាលអញ្ចេះ គេរើស ខ្ញុំក៏មិនដឹងដែរ ធ្វើការៗទៅ គេថាឲ្យរើសនារី៦០នាក់ហើយុវជន៦០នាក់ គេថាឲ្យដើរទៅមើលទៅធ្វើទស្សនកិច្ចទៅណា គេថាទៅណា គេនិយាយអីចឹងទៅណា គេក៏នាំទៅ ហើយម្នាក់ៗក៏នាំគ្នាមកនៅផ្ទះគាត់ មកឈប់ដាំបាយនៅផ្ទះគាត់ហ្នឹងឯង ។ សុទ្ធតែប្រកការ៉ុង ។

ប្រុញ ៖ ឈប់ផ្ទះតាវ៉ាលហ្នឹង?

ផាន ៖ ចា៎! មួបអីក៏ដាក់ទៅ ទៅដល់សៀមរាប ។ ទៅដល់សៀមរាប ទៅមើលអង្គរវត្តហើយ ទៅក៏មកវិញទៅ ។ គាត់ថាទៅស្ទឹងគេ ទៅកោះកុងស្ទឹងទៀតទៅភូមិខ្ញុំក៏មកដល់ទៅញាក់ទាំងអស់គ្នា ។ នេះទៅ អត់មាននរណាបានទៅទៀតទេ ។

ប្រុញ៖ ដល់ពេលអ្នកដែលគេរើសទៅហ្នឹង គាត់មកវិញធ្វើអីទៀតទៅ គាត់ធ្វើការហ្នឹងដដែរ ឬក៏គាត់ដឹកនាំក្រុម ដឹកនាំកងទៅ?

ផាន ៖ អត់ទេ ឲ្យធ្វើការដដែរ ។ ធ្វើការខ្លួនឯងដដែរ ។

ប្រុញ ៖ ហើយចុះអ្នកមីងជួបប្រជុំ និងប្រធានកងជួបប្រជុំជាមួយតាវ៉ាលហ្នឹងញឹកញាប់ដែររឺទេ?

ផាន ៖ ទេ អត់ទេ ។

ប្រុញ ៖ ដោយសារគាត់ធំយើងអត់បានជួបគាត់រឺមួយក៏យ៉ាងម៉េច?

ផាន ៖ ទេ អានេះអត់បានគិតទេ ។ ដូចថាគេហៅទៅប្រជុំឯលើ ទៅរៀនសូត្រឯលើ ទៅមែនទៅ តែគាត់អត់ដែរទៅទេ ទៅគេអ្នកផ្សេង គេបង្រៀនផ្សេងទៅ គាត់នៅតែកន្លែងហ្នឹងហើយ ។

ប្រុញ ៖ ពេលដែលទៅធ្វើការហ្នឹងភាគច្រើនមកពីណាវិញ អ្នកមីញ? មកពីភ្នំពេញច្រើនទេ អ្នកមីង ឬមួយយ៉ាងម៉េច?

ផាន ៖ ប្រជាជនតាមភូមិតាស្រុក ។

ប្រុញ ៖ ត្រពាំងថ្មហ្នឹងធំទេ?

ផាន ៖ ធំតើ ត្រពាំងហ្នឹង ល្អរល្អេវ ធំណាស់ ។

ប្រុញ ៖ ឥឡូវនៅប្រើរាល់ថ្ងៃទេ?

ផាន ៖ អូ! ទឹកសព្វថ្ងៃហ្នឹង គេហៅអាងត្រពាំងថ្ម ធំណាស់ និយាយពីមើលទៅ ទឹកដាច់កន្ទុយភ្នែក ។ ទឹកហ្នឹង ។

ប្រុញ ៖ ត្រូវប្រើកម្លាំងមនុស្សច្រើនណាស់មើលទៅអ្នកមីង?

ផាន ៖ ចាំ! ច្រើនណាស់ ។

ប្រុញ ៖ ចុះអាចម៍ដីហ្នឹងគេយកទៅឯណាវិញទៅអ្នកមីង?

ផាន ៖ ដីគេជីកពីក្រោម ពីបាតក្រោមយកមកដាក់ពីលើខ្នងទំនប់ ។

ប្រុញ ៖ ចុះត្រពាំងទំនប់ហ្នឹងដាក់អស់ដែរ ព្រោះដីច្រើនអីចឹង? អត់អីទេ?

ផាន ៖ ជីកមកដូចថាជីកត្រង់ទៅអញ្ចេះៗ ជីកដូចថាជីកធ្វើប្រឡាយ ។ ដល់សព្វថ្ងៃនេះ ទប់បានហើយ ទឹកល្អរល្អេវ ។

ប្រុញ ៖ អូ! យល់ ។ មានន័យថា ការពិតទៅស្មានថាជីកយកទំហំដីទាំងអស់ តាមពិតទៅយើងជីកលើកទំនប់ឲ្យខ្ពស់?

ផាន ៖ ចាំ ។ យើងដាក់លើខ្នងទំនប់ឲ្យខ្ពស់ វែកពីក្រោមមកដាក់ឲ្យខ្ពស់ ធ្វើប្រឡាយទឹកមួយបង្ហូរវា តាមជើងទំនប់សុទ្ធតែប្រឡាយទឹក ។ បង្ហូរ ។

ប្រុញ ៖ កាលហ្នឹងគេហូបអីគ្រប់គ្រាន់ដែរទេ? ពេលធ្វើទំនប់ហ្នឹង?

ផាន ៖ ទេ ។ ពេលខ្ញុំនៅចល័តហ្នឹងបានហូបគ្រប់គ្រាន់ ។

ប្រុញ ៖ ពេលចល័តពេលធ្វើនៅត្រពាំងថ្មហ្នឹង បានហូបគ្រប់គ្រាន់?

ផាន ៖ ចាំ! ហូបគ្រប់គ្រាន់ដែរ ។

ប្រុញ៖ ចុះអ្នកផ្សេងៗទៀតអ្នកមីង?

ផាន ៖ ហូបដូចតែគ្នាហ្នឹង បើមិនឲ្យហូបច្រើនអីចឹងមានកម្លាំងឯណាមកវែកដីឲ្យទៅ ។

ប្រុញ ៖ ជម្ងឺអីយ៉ាងម៉េចដែរ អ្នកមីង?

ផាន ៖ ជម្ងឺហ្នឹងមានដែរ មានឈឺស្លាប់ខ្លះ រស់ខ្លះ មើលមិនជា ។ ខ្ញុំអស់ប្អូនជីដូនមួយខ្ញុំម្នាក់ដែរស្លាប់ដោយសារតែលើកទំនប់ហ្នឹងណា ។

ប្រុញ ៖ ប្អូនអ្នកមីង?

ផាន ៖ ប្អូនជីដូនមួយ ។

ប៊ុនថន ៖ ឈឺអីវិញ អ្នកមីង?

ផាន : វាភាគមួល ភាគមួលទៅក៏មើលអត់ជាទេ ។ ពេទ្យគេចាក់ថ្នាំចាក់អីឲ្យហើយ ក៏មើលអត់ជាដែរ ហើយក៏ងាប់ទៅ ងាប់អស់មួយ ។ ងាប់ទៅក៏យកទៅកប់នៅឯណាឯណៃទៅ ។

ប៊ុនថន : បាទ! អត់បានយកមកភូមិយកមកអីទេ?

ផាន : អត់បានយកមកភូមិទេ ហើយសូម្បីតែខ្ញុំនេះក៏មិនបានទៅមើលប្អូនងាប់ទៀត ។

ប្រុញ : អាហ្នឹងដោយសារតែគាត់ហូបទឹកអត់សូវល្អ ឬមួយក៏យ៉ាងម៉េច?

ផាន : ចា៎! ហូបរៀងអត់ទៅ ដោយសារតែវាឈឺជម្ងឺអីចឹង គេមិនសូវឲ្យហូបបរិបូណ៌ទេ ។ ទៅដេកពេទ្យអីហ្នឹងអត់មានអនាម័យទេ ពេទ្យគេឲ្យដេកដែរ តែអត់មានអន័យទេ ។

ប្រុញ : គាត់ធ្វើការច្រើន ហើយដល់ពេលហូបអត់មានអនាម័យទៅជាឈឺ ។ កាលហ្នឹង មានស្លាប់ច្រើនទេ?

ផាន : ស្លាប់ច្រើនគ្រាន់ដែរហ្នឹង ។

ប្រុញ : ប្រហែលប៉ុន្មានទៅ?

ផាន : ស្លាប់អាអ្នកចុះភាគ មើលមិនជា គ្រុនចាញ់ ។

ប្រុញៈ ប្រហែលប៉ុន្មានដែរទៅ?

ផាន : ច្រើនដែរហ្នឹង ។ តែអានេះបានទៅសួរពួកពេទ្យៗបានដឹង ។

ប្រុញ : ចុះអ្នកដែលស្លាប់នៅកន្លែងហ្នឹង?

ផាន : អ្នកស្លាប់នៅកន្លែងហ្នឹងអត់មានទេ ។ មានតែអ្នកទៅស្លាប់នៅកន្លែងមន្ទីរពេទ្យគេ ។

ប្រុញ : ពេលឈឺហើយ គេបញ្ជូនទៅមន្ទីរពេទ្យ?

ផាន : ឲ្យតែឈឺហើយមិនបានទៅធ្វើការកើត គេបញ្ជូនទៅពេទ្យ ។

ប្រុញ : ស្លាប់អីហ្នឹងអាចចូលដល់ពាន់នាក់ដែរទេមីង ដោយសារជម្ងឺអី?

ផាន : មិនដឹងជាយ៉ាងណាទេ មិនសូវដឹងដែរ ។

ប្រុញ : ចុះដល់ពេលយប់ទៅគេសម្រាកនៅឯណាវិញអ្នកមីង?

ផាន : គេធ្វើរោងនៅ រោងវែង គេដាក់ឲ្យដេកទៅ ។

ប្រុញៈ អូ! នៅតាមទំនប់ហ្នឹងនៅកន្លែង?

ផាន : នៅតាមជើងទំនប់ហ្នឹង គេធ្វើរោងនៅតាមជើងទំនប់ហ្នឹងឯង ។

ប៊ុនថន : អូ! យើងធ្វើការកន្លែងណាទៅ គេធ្វើរោង?

ផាន : ចា៎! គេធ្វើរោងឲ្យដេកទៅ ។

ប៊ុនថន : ចុះអ្នកមីងទៅនោះដូចអាហារអីគេហូបយ៉ាងម៉េចដែរ? គេបែកចែកឲ្យហូបតាមកង?

ផាន : ហូបតាមកង ។ ហូបតាមកង គេយកមកតាមកងហ្នឹង គេចែកតាមក្រុមហូបទៀត ។

ប៊ុនថន : ក្រុមមីងមាន?

ផាន : ម៉ាក្រុម១០នាក់ឲ្យហូប ។

ប្រុញ : ម៉ាកងមានប៉ុន្មាននាក់?

ផាន : ម៉ាកងតូចមាន៣០នាក់ ។ ក្នុងម៉ាកងតូចហ្នឹងមានសាមសិបនាក់ហ្នឹងវាមានបីក្រុម ។ ហើយមេក្រុមទៅយកមកហើយក៏ហៅគេចែកទៅ ។

ប៊ុនថន : ម្នាក់គេចែកប៉ុន្មានកាលនៅនោះ?

ផាន : កាលនៅនោះ គេហូបម៉ាវែ្ឆតដែរ មិនហូបខ្វះខាតទេ ។ ជារឿងម្ហូបវារៀងខើច បើថាគេរកក្រៅ បើទៅរកហូបក្រៅ គេអត់ឲ្យរកទេ គេឲ្យហូបរួមតែម្តង ។

ប៊ុនថន : យ៉ាងម៉េចដែរ អ្នកមីង?

ផាន : ខ្វះទៅ ជួនកាលគ្នាដូចថាប្រជាជនថ្មីទៅ គាត់ហូបមិនគ្រប់ទៅ គាត់ក៏ទៅអួសត្រីអួសអីទៅ ។ ហើយយើងប្រធានកងចេះតែបិទភ្នែកទៅ ឲ្យគ្នារស់ផង ។ បើថាអ្នកមិនចេះបិទភ្នែកទៅ ក៏ទៅរាយការណ៍ទៅ ក៏យ៉ាប់គ្នាទៅ គេចាប់គ្នាទៅ ។ ដូចនៅក្រុមខ្ញុំអត់ដែរទេ ធ្វើម៉េចបាននេះក៏ចេះតែហូបៗទៅ បានម៉ារស់ៗទាំងអស់គ្នាទៅ ខ្ញុំមិនដែរទេ ។

ប៊ុនថន : អីចឹងមានអ្នកត្រូវបានគេចាប់ដោយសារតែអួសត្រីអីដែរអ្នកមីង?

ផាន : មាន គេចាប់ដែរ ។

ប្រុញ: ចាប់ហ្នឹងគេយកទៅអប់រំ យ៉ាងម៉េចដែរ?

ផាន : គេយកទៅអប់រំណែនាំកុំឲ្យយើងរកហូបតាមឯកជន គេឲ្យយើងហូបរួម ។

ប្រុញ : ចុះការអប់រំហ្នឹង គេយកទៅអប់រំដល់ណាទៅ?

ផាន : អប់រំនៅគ្រប់កន្លែងហ្នឹងឯង ។ គេហៅទៅកសាង អប់រំឲ្យយើងឈប់ទៅរកហូបឯកជនហូបយើងហូបរួម គេថាបើហូបរួមគេអត់ថាទេ តែបើហូបឯកជនតែម្នាក់យើងគេថាឲ្យ ។

ប៊ុនថន : ចុះម្ហូបហ្នឹងមានអីខ្លះទៅ អ្នកមីង?

ផាន : មិនសូវមានអីទេ កាលណាក៏មានម្ជូរត្រកួនម្ជូរប្រលិតហ្នឹងហើយ ។

ប្រុញ : មានបាយមានបបរអីចឹងទៅ?

ផាន : មានបាយ ។

ប្រុញ : បាយហ្នឹងគេឲ្យហូបបាយទូទៅតែម្តងរឺមានខែគេឲ្យហូបដែរ?

ផាន : ទេ គេហូបទូទៅ លើកទំនប់អីចឹងគេឲ្យហូប ។

ប្រុញ ៖ ហូបបាយ អត់ដែលហូបបបរទេ?

ផាន ៖ អត់ដែរហូបទេបបរហ្នឹង ហូបតែបាយ ។

ប៊ុនថន ៖ ចុះដូចថាការហូបហ្នឹងដូចមីងនិយាយអំបាញ់មិញថាអត់សូវខ្វះខាតខ្លាំងទេ?

ផាន ៖ កណ្តាលធម្មតា ។

ប្រុញ ៖ ចុះទឹកហូបនៅហ្នឹង?

ផាន ៖ អត់ទេ ទឹករៀងខើចដែរ ។ ទឹកគេដឹកមកឲ្យហូប ។ អត់មានទេទឹក ។ គេដឹកយកមកដាក់ ។

ប្រុញ ៖ ចុះផ្ទូតទឹកអីយ៉ាងម៉េចទៅ អត់បានផ្ទូតទេ?

ផាន ៖ ទឹកផ្ទូតមានដែរ តែវាមិនសូវថ្លាទេ វារៀងល្អក់ៗ ។

ប្រុញ ៖ អីចឹងនៅជិតហ្នឹងអត់មានទឹកឯណាផ្ទូតបានទេ?

ផាន ៖ មានទឹកតាមភូមិ ដូចក្នុងភូមិត្រពាំងថ្ម ស្រះអីក៏នាំគ្នាដើរមកផ្ទូត ។ ធ្វើការឡើងពីថ្ងៃក៏នាំគ្នាឡើងមកផ្ទូតទៅ ។

ប៊ុនថន ៖ ចុះអ្នកមីងក្រុមអ្នកមីងដែលមកលើកហ្នឹងមានផ្លាស់ប្តូរអីដែរទេ ឬមួយក៏នៅដដែរ? មីង?

ផាន ៖ នៅដដែរ ។

ប៊ុនថន ៖ ម៉ាកងតូចរបស់អ្នកមីង?

ផាន ៖ ចាំ!

ប៊ុនថន ៖ ហើយម៉ានៅហ្នឹងមានអ្នកឈឺអីដែរទេ?

ផាន ៖ មានដែរតែមិនមែនបានដេកពេទ្យអីទេ គ្រាន់តែឈឺសម្រាកមួយថ្ងៃពីរអីហ្នឹងក៏ជាទៅ ដូចថាឈឺក្បាលវិលមុខអីហ្នឹង លេបថ្នាំបន្តិចបន្តួចទៅ ថ្នាំគេបើកឲ្យហ្នឹង ហើយក៏ជាទៅ ។

ប្រុញ ៖ មានថ្នាំមានអីឲ្យលេបដែរអ្នកមីញ?

ផាន ៖ មាន ។

ប្រុញ ៖ ថ្នាំភាគច្រើនយកមកពីណាវិញ?

ផាន ៖ ចាំ! ថ្នាំហ្នឹងមិនដឹងជាមកពីខាងណាវិញទេ ។ គេទៅបើកទៅ ហើយបានអាហ្នឹងមក ។

ប៊ុនថន ៖ ហើយចុះអ្នកមីងលើកហ្នឹងមានដូចថាផ្លាស់ប្តូរប្រធានកងអីទេ? អ្នកមីង?

ផាន ៖ អត់មានផ្លាស់ទេ ។

ប៊ុនថន ៖ កងផ្សេងៗក៏អត់មានផ្លាស់ដែរ?

ផាន ៖ អត់មានផ្លាស់ទេ ។

ប៊ុនថន ៖ ហើយអ្នកមីងការងារមានបន្ថែមអីទៀតទេ ក្រៅពី?

ផាន ៖ អត់ទេអត់មានបន្ថែមទេ ។

ប៊ុនថន ៖ បាទ!

ផាន ៖ ទូទៅ ។

ប្រុញ ៖ ចុះជំនាន់ហ្នឹងក្រៅពីស្លាប់ដោយសារជម្ងឺអីហ្នឹង មានស្លាប់ដោយសារតែគាត់ធ្វើទង្វើអីខុស ទើបគេយកទៅសម្លាប់អីទេ អ្នកមីង?

ផាន ៖ អត់ទេ ។

ប្រុញ៖ អីចឹង ស្លាប់ភាគច្រើនដោយសារជម្ងឺតែម្តង?

ផាន ៖ ចា៎!

ប្រុញ ៖ ជម្ងឺដោយសារធ្វើការធ្ងន់ៗ នៅហ្នឹងមានចម្រុះជនជាតិតែម្តងឬយ៉ាងម៉េច? ឧទាហរណ៍ ដូចថាមានខាងអ្នកមកពីភ្នំពេញ ឬមកពីភូមិហ្នឹង? ជនជាតិចាម ឬយ៉ាងម៉េចដែរ?

ផាន ៖ ចា៎! តែខ្ញុំឃើញមានតែចិនច្រើន ។

ប្រុញ ៖ មានចិន ហើយចុះវៀតណាម?

ផាន ៖ អត់ទេ មិនដែលឃើញទេ ។

ប្រុញ ៖ ចិនហ្នឹង ភាគច្រើនមកពីភ្នំពេញ អ្នកមីង?

ផាន ៖ អត់ទេ មកពីខាងណោះឯង ។ ខ្លះអត់ស្គាល់ដើមស្មោរផងហ្នឹង ។ ឈ្លើងក៏ស្គាល់ដែរ ។ ឃើញឈ្លើញអីចឹង ចាប់ថានេះ ។ ខ្ញុំខ្លាចឈ្លើងណាស់ ។

ប៊ុនថន ៖ ចុះមីងអ្នកថ្មីមកអីចឹងការងារស្មើគ្នាឬមួយក៏?

ផាន ៖ ស្មើគ្នា ។

ប៊ុនថន ៖ ចុះរបបអាហារអីហ្នឹង?

ផាន ៖ ដូចគ្នា ។

ប៊ុនថន ៖ ដូចថាអ្នកដែលមកហ្នឹងអត់ធ្លាប់វែកអីចឹង យ៉ាងម៉េចដែរ អ្នកមីង ដូចថាអត់ធ្លាប់វែកអីចឹង?

ផាន ៖ អត់ធ្លាប់វែក ត្រូវរៀន ហាត់ពុតលុតដុំ គេបំពាក់បំប៉នថាឲ្យហាត់ពុតលត់ដុំ ហើយវែកកើតដូចគ្នា ។

ប្រុញ ៖ ចុះមានគេនិយាយថា ឧទាហរណ៍ដូចថាយើងវែកអត់បាន គេគំរាមយើងថាត្រូវធ្វើទណ្ឌកម្មអី មានទេមីង?

ផាន ៖ អត់ទេ អត់មានគំរាមទេ ។

ប្រុញ ៖ អីចឹងធ្វើយ៉ាងម៉េចត្រូវធ្វើឲ្យហើយដីដែលគេរាស់ឲ្យហ្នឹង?

ផាន ៖ ចា៎! តែគេអត់គំរាមទេ ។

ប៊ុនថន ៖ អីចឹង អ្នកមីងអ្នកដែលគ្រប់គ្រងរួមជានរណាវិញ អ្នកក្តាប់រួមហ្នឹង?

ផាន ៖ អ្នកក្តាប់រួមហ្នឹង មានតែគាត់ហ្នឹងឯង តាវ៉ាលហ្នឹង ។

ប៊ុនថន ៖ អីចឹង អ្នកនៅហ្នឹងមានពីណាវិញ អ្នកដែលមកពីតំបន់ប្រាំហ្នឹង ឬក៏មកពីតំបន់ផ្សេងៗទៀត?

ផាន ៖ រួមតែម៉ាតំបន់ប្រាំហ្នឹងឯង ។ ទាំងអស់គ្នា ។

ប៊ុនថន ៖ ពីស្រុកណាខ្លះអ្នកមីង?

ផាន ៖ ពីខាងថ្មពួក ពីខាងអីហ្នឹង រួមគ្នា ធ្វើទំនប់អាងត្រពាំងថ្មហ្នឹង ។

ប៊ុនថន ៖ ភ្នំស្រុក?

ផាន ៖ ចា៎!

ប៊ុនថន ៖ ភ្នំស្រុកមកត្រពាំងថ្មដែរ?

ផាន ៖ ចា៎! ខាងស្ពានស្រែងអីហ្នឹងមកធ្វើរួមទាំងអស់គ្នា ។ តែម៉ាតំបន់ប្រាំតែម្តង ។

ប្រុញ ៖ តាវ៉ាលហ្នឹងគាត់ត្រូវជាយ៉ាងម៉េចដែរ គាត់មានឋានៈអីដែរ?

ផាន ៖ ខ្ញុំមិនដឹងដែរ គាត់ដូចជាប្រធានក្តាប់រួមម៉ាតំបន់ប្រាំ ។

ប្រុញ ៖ ប្រធានគណៈតំបន់ប្រាំតែម្តង?

ផាន ៖ ចា៎! គាត់ក្តាប់រួមខាងការងារចុះខាងទំនប់ ។

ប្រុញ៖ អីចឹងគាត់នៅក្តាប់រួមហ្នឹង រហូតទាល់តែធ្វើហើយ ទើបគាត់ដឹកនាំទៅធ្វើនៅស្ពានស្រែងទៀត?

ផាន ៖ ចា៎! ទៅស្ពានស្រែងទៀត ។

ប្រុញ ៖ ហើយចុះក្រោយពីគាត់ដឹកនាំទៅ មាននរណាទៀតដែលធ្វើកាន់នៅត្រពាំងថ្មហ្នឹងទៀតអីអត់ទេ?

ផាន ៖ អត់មាននរណាទៀតទេ ។ មានតែគាត់ហ្នឹង ។

ប៊ុនថន ៖ ចុះអ្នកមីងត្រពាំងថ្មហ្នឹងមីងមានដឹងថាវាទំហំប៉ុន្មានៗទេ? អ្នកមីង? មានគេប្រជុំប្រាប់អីទេ

ផាន ៖ អត់ទេ គេអត់ទេ ។ ដូចជាធ្លាប់លឺដែលតែខ្ញុំដូចជាភ្លេចហើយ យូរហើយ ធ្លាប់លឺ បើមិន ៥ ម៉ែត្រ អាហ្នឹងខ្នងទំនប់ ។

ប៊ុនថន ៖ ហើយចុះបាតទំនប់?

ផាន ៖ អាបាតក្រោមនោះ ដូចជា ១០ ។

ប៊ុនថន ៖ ១០ ម៉ែត្រ ។ ហើយចុះបណ្ដោយវិញ? អ្នកមីង?

ផាន ៖ បណ្ដោយហ្នឹងវែងណាស់ ។

ប៊ុនថន ៖ ប្រហែលជាប៉ុន្មានគីឡូ?

ផាន ៖ តាំងពី ចាប់តាំងពីជិតទន្លេហ្នឹងរហូតទៅដល់ភ្នំស្រុករហូតហួសទៅដល់នេះទៀត ហួសភ្នំកូនខ្វែងទៀត ច្រើនណាស់ ។

ប៊ុនថន ៖ បាទ! អីចឹងមីងធ្វើនៅហ្នឹងរហូតដល់ចប់រឺមានដកចេញមក?

ផាន ៖ ធ្វើរហូតដល់ចប់ចុងចប់ដើមទើបដកកម្លាំងទៅធ្វើអាខាងស្ពានស្រែងទៀត ។

ប្រុញ ៖ ស្ពានស្រែងធ្វើហើយទេ?

ផាន ៖ ធ្វើហើយ ចាក់ជិតអស់ ។

ប៊ុនថន ៖ ចុះកម្លាំងមីងមានបាត់ខ្លះទេ ឬក៏នៅជុំទាំងអស់?

ផាន ៖ ចា៎! ជុំ ធ្វើជុំគ្នាទាំងអស់អត់មានបាត់ទេ ។

ប្រុញ ៖ ហើយចុះជនជាតិចិនហ្នឹងនៅរស់ទាំងអស់អត់មានសម្លាប់អីទេ?

ផាន ៖ ទេ អត់មានទេ ។

ប្រុញ ៖ ចុះគាត់ស្លាប់ច្រើនទេ គាត់ជនជាតិចិនហ្នឹង?

ផាន ៖ ទេ អាហ្នឹងបើគាត់ងាប់ដោយសារជម្ងឺអីខ្ញុំអត់ដឹងទេ ។ តែបើក្នុងធ្វើការ គាត់ដូចជាអត់បាត់ទេ ។

ប្រុញ ៖ ចុះអ្នកមកពីភ្នំពេញ ភាគច្រើននរណាវិញ?

ផាន ៖ ខាងអរិយក្សត្រ គេថាឈ្មោះ ខ្ញុំលឺអ្នកនៅក្នុងក្រុមខ្ញុំគេថា មានខាងអរិយខ្សាច់ផង ខាងកំពង់ចាមកំពង់អីផង លាយគ្នាដែរតើ ។

ប្រុញ ៖ មីងមានដឹងថាមូលហេតុអ្វីបានជាពួកគាត់ត្រូវបានគេបញ្ជូនមកហ្នឹងទេ?

ផាន ៖ ខ្ញុំមិនដឹងដែរ លឺថាគេជម្លៀសមកដូចគ្នា ។

ប៊ុនថន ៖ ជម្លៀសហ្នឹងគេមកក្រោយអ្នកមីងយូរដែររឺក៏យ៉ាងម៉េចដែរ?

ផាន ៖ មកក្រោយ ហើយដល់ត្រឡប់ចេញទៅធ្វើការទៅក៏ស្គាល់ទៅ វែកជុំគ្នាហើយក៏សួរនាំទៅថានៅឯណាស្រុកកំណើតនៅឯណា ។ ខ្ញុំសួរ គាត់ថាទៅ ខ្លះនៅអរិយខ្សាច់ គាត់និយាយ ។

ប៊ុនថន ៖ ចុះអ្នកមីងចេញពីហ្នុងទៅ ទៅស្ពានស្រែងហ្នឹងមីងទៅលើករយៈពេលប៉ុន្មាននៅទីនោះ?

ដាន : ទៅស្ពានស្រែងហ្នឹងយូរដែរហ្នឹងណា ។

ប៊ុនថន : ប្រហែលជារយៈពេលប៉ុន្មានទៅ?

ដាន : ប្រហែលជាបួនប្រាំខែ ។ ទៅបួនប្រាំខែ លើកអានោះជិតចប់ទៅ ខ្ញុំក៏ឈឺ ឈឺទៅខ្ញុំក៏មក ដេកពេទ្យម្ដង ។

ប៊ុនថន : មីងឈឺអីអ៊ី?

ដាន : ខ្ញុំអត់ស្រួលទេ ដូចថារៀងរោគខ្ញុំពីសង្គមចាស់ ដូចជារៀងរោគត្រូវរបស់គេ ហើយដល់ មកដឹកថ្នាំខ្មែរ រកដឹកថ្នាំខ្មែររកគ្រូខ្មែរមើល ។

ប្រុញ : នៅស្ពានស្រែងហ្នឹងធ្វើទំនប់ដែរអ្នកមីង?

ដាន : វែកដី ជីកបិទស្ទឹង បិទស្ពាន បិទស្ពានឆ្លងហ្នឹង បិទឡើងជិតឆឹងទាំងអស់ ។ ចា៎!

ប្រុញ : ហើយធ្វើគ្នាច្រើននាក់ទេ?

ដាន : អូ! ច្រើន ។ ខាងតំបន់បី ។

ប្រុញ : ខាងតំបន់បីអ្នកធ្វើវិញ?

ដាន : ខាងតំបន់បីចាក់ដល់គ្នា ខាងតំបន់ប្រាំចាក់ដល់គ្នា ជិតគ្នា ចាក់ដល់មុខគ្នា ។

ប្រុញ : ស្ទឹងហ្នឹងប្រហែលប៉ុន្មានម៉ែត្រទៅអ្នកមីង?

ដាន : ស្ទឹងហ្នឹងវែងណា៎ ។ យ៉ាងល្ហូរល្ហេវដែរហ្នឹងណា ។

ប្រុញ : ហើយមានទឹកនៅក្នុងហ្នឹងទេ?

ដាន : មាន ។

ប្រុញ : ហើយយើងចាក់ដីចូលក្នុងហ្នឹង?

ដាន : ចាក់ចូលយ៉ាងជិត ហើយខាងប្រាំងអីចឹងវាឡើងរីងទឹកជិតអស់ នៅតិចៗ ទាល់តែចាក់ ហើយអីចឹងទៅ ពួកខ្ញុំវែកដីទៅ មានកងពួកខ្ញុំ ហើយមានកងគេប្រុសៗ ជីកកប់ទៅ ក៏ដី បាក់សន្តត់ ។ និយាយពីថ្ងៃពេញបោរ និយាយប្រាំបី ថ្ងៃដាច់ មានឃើញក្រពើ ដូចថា ក្រពើរបស់អ្នកតាគេថែរក្សា ។ សន្ធឹងឲ្យឃើញ ។

ប្រុញ : ឃើញរាល់ថ្ងៃហ្នឹងរឺយ៉ាងម៉េចដែរ?

ដាន : អត់ទេ ឃើញតែថ្ងៃពេញបោរ ។

ប្រុញ : អត់ទេ ប៉ុន្តែឃើញមកដល់ឥឡូវហ្នឹងឬក៏យ៉ាងម៉េច?

ដាន : សព្វថ្ងៃហ្នឹងមិនដឹងជាយ៉ាងណាទេ ។

ប្រុញ : ឃើញហ្នឹងក្នុងសម័យប៉ុលពតហ្នឹង?

ផាន ៖ ចាំ! ដូចថាផុតអីចឹងទៅ ទឹកវាមានច្រើន ដល់ខែវស្សា ។ ទំនប់បិទនេះណា ។ ដល់នេះទៅ ក៏គេឃើញ គេថាសុំ ចង់ឃើញ ហើយគេក៏សុំថា លើកដៃបួងសួង សុំតែចង់ឃើញរួចពិតជាឲ្យឃើញមែន ។

ប៊ុនថន ៖ ចុះអ្នកមីងទៅហ្នឹង មីងដឹកនាំកម្លាំងមីងទៅដដែរទេ?

ផាន ៖ ដដែរ ។

ប៊ុនថន ៖ ហើយប្រធានកងធំទៅពីត្រពាំងថ្មដែរ?

ផាន ៖ ចាំ! ទៅទាំងអស់គ្នា ។ ដកទៅទាំងអស់ ។ ហើយរួចពីនេះទៅ ដកទៅខាងនោះទាំងអស់ ។

ប្រុញ ៖ អីចឹង តាមការពិតកម្លាំងនៅនោះធ្វើច្រើនណាស់ ដោយសារតែយកពីកម្លាំងនេះទៅទាំងអស់ហើយ ហើយយកពីតំបន់បីមកទៀត?

ផាន ៖ ចាំ!

ប្រុញ ៖ អីចឹង ដីដែលត្រូវចាក់ហ្នឹង ទទឹងវាប៉ុន្មានទៅ?

ផាន ៖ វែងគ្រាន់ដែរ ។

ប្រុញ ៖ មិនមែនបណ្ដោយដីចាកអញ្ចេះទេ ទទឹងទំនប់?

ផាន ៖ ទទឹង ២០ ម៉ែត្រ ក៏មិនដឹង ។

ប្រុញ ៖ ប្រហែល ២០ ម៉ែត្រ?

ផាន ៖ ចាំ! ទេ ។ ដូចជាវែងដែរណាំ ។ ស៊ីងបត់ស៊ីងអញ្ចេះមក គេចាក់ពីនោះមក ហើយក្រុមខ្ញុំគេចាក់ពីនេះទៅវិញដែរ ។

ប្រុញ ៖ ចាក់ហ្នឹងប្រហែលជាខ្វង់ឆ្នាំប៉ុន្មានដែរអ្នកមីង?

ផាន ៖ អឺម! សួរឆ្នាំ ខ្ញុំ ។

ប្រុញ ៖ ប៉ុន្តែដឹងតែក្រោយពីត្រពាំងថ្ម?

ប៊ុនថនៈ ជិតបែកហើយ?

ផាន ៖ ចាំ!

ប៊ុនថន ៖ ហើយចុះតំបន់បីខាងណាអ្នកដឹកនាំធ្វើវិញ? នរណាអ្នកដឹកនាំ?

ប្រុញ ៖ ស្លាប់មនុស្សច្រើនទេ?

សម្លេងមនុស្សប្រុសចាស់ ៖ ... ប្រសិនជាយើងអាចរត់ដូចតំបន់បីប្រហែលអាចរស់ ។

ប៊ុនថន ៖ ខាងតំបន់បីហ្នឹងតើនរណាជាអ្នកដឹកនាំមកធ្វើវិញ អ្នកមីង?

ផាន ៖ ពេលខ្លះ តំបន់បីអត់បានមកលើកខាងនេះទេ ។

ប៊ុនថន ៖ ចុះអ្នកមីងមានស្គាល់ ដូចថានៅធ្វើការជិតក្នារអី មីងមានស្គាល់ទេ?

ផាន ៖ អត់ទេ អត់មានស្គាល់ទេ ។ មានតែខាងសៀមរាប ។ ខាងសៀមរាបគេហៅថាតំបន់អី ខ្ញុំអត់ដឹងទេ ខ្ញុំភ្លេចហើយ ។ ខាងសៀមរាបគេហៅថាតំបន់អី ។

ប៊ុនថន ៖ អត់អីទេមីង ខ្ញុំគ្រាន់តែចង់សួរអ្នកដែលដឹកនាំធ្វើការងារអីអីចឹង ដូចជាតាវ៉ាលអីចឹងណា ដូចថាគណៈតំបន់បីហ្នឹងឈ្មោះអីអីចឹងណា ។

ផាន ៖ ទេ ខ្ញុំអត់ស្គាល់ទេ តំបន់បីហ្នឹង ។

ប៊ុនថន ៖ ចុះអ្នកមីងមកដេកពេទ្យហ្នឹង មីងមកដេកពេទ្យណាវិញ?

ផាន ៖ ខ្ញុំមកដេកពេទ្យភ្នំស្រុក ។

ប៊ុនថន ៖ ភ្នំស្រុក ។ អាហ្នឹងគេហៅថាពេទ្យអីវិញ?

ផាន ៖ គេហៅថាពេទ្យស្រុកតែម្តង ។

ប៊ុនថន ៖ ពេទ្យស្រុក ។

ផាន ៖ ពេទ្យតំបន់នៅត្រពាំងថ្ម ប្រចាំការ ។

ប៊ុនថន ៖ ពេទ្យតំបន់នៅត្រពាំងថ្មវិញ?

ផាន ៖ ចាំ!

ប៊ុនថន ៖ នៅផ្ញុំណា អ្នកមីង? ឥឡូវៗ នៅភូមិអីគេ?

ផាន ៖ នៅត្រពាំងថ្មហ្នឹងហើយ នៅកន្លែង កាលហ្នឹងនៅទីនវត្តហ្នឹងពេទ្យត្រពាំងថ្មហ្នឹង ។ វត្តត្រពាំងថ្មហ្នឹងឯង ។

ប៊ុនថន ៖ បាទ! ពេទ្យតំបន់នៅហ្នឹងតែម្តង?

ផាន ៖ ចាំ! តំបន់ប្រាំនៅហ្នឹង ។

ប៊ុនថន ៖ ចុះអ្នកមីងចេញមកព្យាបាលហើយហ្នឹង មីងមានត្រឡប់ទៅវិញទេ?

ផាន ៖ ខ្ញុំហ្នឹង?

ប៊ុនថន ៖ បាទ!

ផាន ៖ ចេញ ។ ដល់តែខ្ញុំជាវិញ ខ្ញុំអត់បានទៅវិញទេ ខ្ញុំនៅក្នុងភូមិហ្នឹង តែដល់នេះទៅ គេរកចាប់កម្លាំង ។ គេរកចាប់ខ្ញុំទៅវិញ តែខ្ញុំអត់ទៅវិញទេ ខ្ញុំក៏ចូលក្នុងកន្លែងនេះតែម្តង ។

ប៊ុនថន ៖ ចូលនៅឯណា?

ផាន ៖ ចូលនៅកន្លែងសង្កាត់ភូមិគេតែម្តង ។

ប៊ុនថន ៖ ធ្វើការនៅហ្នឹង?

ផាន ៖ ធ្វើការនៅភូមិ ។

ប៊ុនថន ៖ កាលហ្នឹងគេហៅថាសង្កាត់អីវិញមីង?

ផាន ៖ សង្កាត់ព្រះនេត្រព្រះហ្នឹងឯង ។

ប៊ុនថន ៖ កាលហ្នឹងនរណាប្រធានសង្កាត់ហ្នឹង? មីង?

ផាន ៖ តាក្រក ។

ប៊ុនថន ៖ អូ! មីងនៅជាមួយតាក្រកហ្នឹង?

ផាន ៖ ចាំ!

ប៊ុនថន ៖ បាទ! មីងធ្វើការជាមួយគាត់?

ផាន ៖ ចាំ!

ប៊ុនថន ៖ ចុះស្រុកមីងមានស្គាល់ទេ?

ផាន ៖ ស្រុក ខ្ញុំអត់ស្គាល់ទេ ។

ប៊ុនថន ៖ ហើយចុះយាយថែម មីងស្គាល់ទេ? ទឹម ថែម?

ផាន ៖ ខ្ញុំមិនដែលស្គាល់យាយថែមហ្នឹងទេ លឺតែឈ្មោះយាយថែមៗ ហើយគាត់មិនមែននៅនេះឯណា នៅឯភ្នំលាបឯណោះ ។ នៅត្រឡោកភ្នំលាបឯណោះ ។

ប៊ុនថន ៖ អីចឹង គាត់មានកាន់ខាងព្រះនេត្រព្រះដែរ?

ផាន ៖ មិនដឹងដែរ ។ យាយថែមហ្នឹងខាងស្រុកទេ តាវ៉ាលគាត់ខាងក្តាប់រួមខាងទំនប់ ។ គាត់មើលខាងទំនប់ ។

ប្រុញ ៖ មានពីណាគេដែលបន្ទាប់ពីតាវ៉ាលហ្នឹងទៀតទេ?

ផាន ៖ មួយនោះឈ្មោះ បងស៊ិន ។

ប្រុញ ៖ តាស៊ិនហ្នឹង គាត់ធ្វើអីគេ?

ផាន ៖ តាស៊ិនខាងនេះ ខាងទំនប់ហ្នឹង ដូចថានៅការពារគាត់ណាស់ ។ គាត់ដូចជាខាងដាងដែកហ្នឹងឯង ។

ប្រុញ ៖ បន្ទាប់ពីតាវ៉ាល ជួយមើលការងារតាវ៉ាល អីចឹង?

ផាន ៖ ចាំ!

ប៊ុនថន ៖ អីចឹង មីងនៅជាមួយតាក្រកហ្នឹងរយៈពេលប៉ុន្មានមីង?

ផាន ៖ ខ្ញុំនៅមិនយូរទេ នៅមិនបានមួយខែ ។ ទៅនៅឆ្ងាយ ។

សម្ភេនអ្នកជិតខាង ៖ អត់ដឹងច្បាស់ដែរ វាធ្វើយោធាជាមួយគ្នា។ អាហ្នឹងពេលដែលគេចាប់តាម៉ន តាវ៉ាល អីហ្នឹងវានៅជាមួយគ្នាហើយ វាគេចពីហ្នឹង ហើយទៅពួនក្នុងព្រៃ។

ប្រុញ ៖ ឈ្មោះអីគេ?

ផាន ៖ ឡុត សួយ។

សម្ភេនអ្នកជិតខាង ៖ អាហ្នឹងវាច្បាស់ណាស់ព្រោះវាធ្វើទាហានជាមួយ។

ផាន ៖ ដូចថាវាយោធា វានៅជុំគ្នា។

សម្ភេនអ្នកជិតខាង ៖ ថ្ងៃទីប៉ុន្មានខែប៉ុន្មានដែលត្រូវចាប់តាម៉នអីហ្នឹង សួរវា។

ផាន ៖ ហ្នឹងហើយ ដល់មកសួរខ្ញុំ ខ្ញុំអត់ដឹងទេ សួរថ្ងៃទីប៉ុន្មានខែប៉ុន្មាន ខ្ញុំអត់ដឹងទេ។

ប្រុញ ៖ ឈ្មោះ ឡុត សួយ ហ្នឹងនៅជាមួយតាម៉ោន តាវ៉ាល តាសឺន អីហ្នឹង?

ផាន ៖ ហ្នឹងហើយ នៅជុំគ្នាហ្នឹងឯង។

ប៊ុនថន ៖ អ្នកមីងនៅរហូតដល់បែក ៧៩ ហ្នឹងខាងនេះហ្នឹង?

ផាន ៖ ខ្ញុំនៅរហូតទល់តែចប់ចុងចប់ដើម ទើបខ្ញុំមកវិញ។

ប៊ុនថន ៖ បាទ! នៅខាងសង្កាត់នេះ នៅរហូតដល់បែកអ្នកមីង?

ផាន ៖ ចាំ! នៅរហូតទាល់តែសន្តិភាព។ នៅរហូតដល់គេមករំដោះបាន។

ប៊ុនថន ៖ ពេលគេវៃហ្នឹងមីងមកនៅឯណា មីង?

ផាន ៖ ដល់គេក្តុងក្តាំងហ្នឹង ខ្ញុំមកភូមិវិញ។

ប៊ុនថន ៖ មករសនៅផ្ទះនេះរាល់ថ្ងៃហ្នឹង?

ផាន ៖ ខ្ញុំរស់នៅឯតាប៉ែនឯណោះ។

ប៊ុនថន ៖ តាប៉ែន?

ផាន ៖ ចាំ!

ប៊ុនថន ៖ ចុះឆ្នាំប៉ុន្មានមីងមកនៅនេះវិញ?

ផាន ៖ មិនដឹងជាឆ្នាំប៉ុន្មានទេ យូរហើយ។ ពេលយួនចូលហ្នឹងក៏មកភូមិវិញ។ មកនៅតាមភូមិវិញ ៧៩ ហ្នឹង។

ប្រុញ ៖ ពេលហ្នឹងមានសង្គ្រាមទេ ពេលដែលធ្វើការធ្វើអីហ្នឹង?

ផាន ៖ ទេ អត់មានអីទេ អត់មានសង្គ្រាមទេ។

ប្រុញ ៖ ថាពេលធ្វើហ្នឹងមានសង្គ្រាមជាមួយពួកវៀតណាមអីចឹង?

ផាន ៖ អត់ទេ ពេលចូលមកភូមិក៏បានឃើញវៀតណាមគេមកនៅតាមភូមិ អត់មានបានឃើញជួបប្រទះការបាញ់គ្នាអីទេ អត់ទេ។

ប្រុញ ៖ និយាយឲ្យចំទៅ ក្រោយពីលន់លល់គ្រប់គ្រប់ហើយ ខាងខ្មែរក្រហមចូលមក ក៏ធ្វើការឲ្យខ្មែរក្រហមទៅ។

ផាន ៖ ចាំ! អីចឹងឯង។

សម្លេងអ្នកជិតខាង ៖ តែដល់ពេលនេះទៅ ខ្មែរក្រហមធ្វើសកម្មភាពដែរ វាចូលមកយកក្របីយកស្អីរបស់ប្រជាជនហ្នឹង។

ប្រុញ ៖ យកប្រហែលឆ្នាំណាដែរ?

សម្លេងអ្នកជិតខាង ៖ ឆ្នាំ ៧៩ ហ្នឹងឯង។

ប្រុញ ៖ ៧៩ បែកហើយហ្នឹង?

ផាន ៖ បែកហើយក៏វាលួច វាអត់ទាន់ចូលដល់គោលដៅរបស់វាទេ វានៅពួនតាមព្រៃចូលមក។

ប៊ុនថន ៖ អីចឹងចង់សួរអ្នកមីងបន្តិចទៀត អ្នកមីងការនៅឆ្នាំប៉ុន្មានដែរ?

ផាន ៖ ខ្ញុំការនៅពេលខ្ញុំអាយុ ២៥។

ប៊ុនថន ៖ កាលពីជំនាន់ប៉ីឆ្នាំហ្នឹង?

ផាន ៖ ទេ អត់ទេ។ យួន កាលយួនចូលមកនេះ។

ប៊ុនថន ៖ អូ! ពេលក្រោយនេះទេ?

ផាន ៖ ចាំ! ក្រោយយួនចូលមកហើយ។ មុននេះខ្ញុំនៅលីវទេ។

ប៊ុនថន ៖ ហើយក្រោយ ៧៩ មក មីងមានធ្វើអីទៀត?

ផាន ៖ អត់មានធ្វើអីទេ។ យួនចូលមកហើយ ខ្ញុំមកនៅភូមិវិញ។ អត់មានធ្វើអី។

សម្លេងអ្នកជិតខាង ៖ ដល់៧៩ហ្នឹងបានខ្មែរក្រហមចាប់ហ្នឹង ទៅរកត្រី ខ្មែរក្រហមចាប់។

ផាន ៖ ប្រមូលឡើងជិតមួយឆ្នាំ ខុះឡើង នេះមក ខ្ញុំរត់មកដល់បានជិតមួយខែ ទើបមានសន្តិភាព។

ប៊ុនថន ៖ ចាប់រឿងអីដែរអ្នកមីង?

ផាន ៖ ខ្ញុំទៅរកត្រីមកហើយក៏គេចាប់។

ប៊ុនថន ៖ ខាងណាចាប់?

ផាន ៖ ខ្មែរក្រហម។

ប៊ុនថន ៖ គេចាប់យកទៅណា អ្នកមីង?

ផាន ៖ យកទៅនៅឯក្រោមហ្នឹងគេបំពាក់បំប៉ននៅជាមួយគេ ហើយខ្ញុំនៅមិនបានក៏រត់មក ។

ប៊ុនថន ៖ នៅឯក្រោមហ្នឹងនៅឯណាទៅ?

ផាន ៖ នៅព្រៃនាម បាក់ព្រាបាក់អីហ្នឹងណា ។

ប៊ុនថន ៖ នៅជួរបាត់ដំបងនេះ ជួរបាក់ព្រា ។ បាទ!

ផាន ៖ ដល់នេះទៅ ខ្ញុំរត់មកវិញ គ្នាបីនាក់ ។ គ្រាន់តែរត់មកពីនោះ ដេកផ្លូវបីយប់បីថ្ងៃទើបបានដល់ ។

ប៊ុនថន ៖ អីចឹងឲ្យតែអ្នកខុសគេយកទៅកន្លែងហ្នឹងតែម្តង?

ផាន ៖ អត់ទេ ខ្ញុំទៅរកត្រីរួចក៏គេដេញចាប់បាញ់បានទៅ ហើយគេអ្នកណាដែលគេរត់រួចបានទៅក៏រត់រួចទៅ ។ រួចមិនរួចទៅក៏ទៅនៅខាងគេទៅ ។ នៅហ្នុងព្រៃនាម ។

ប្រុញ ៖ និយាយអីចឹង ចង់សួរមីងពាក់ព័ន្ធនឹងតាវ៉ាល តាស៊ន និងតាម៉ោង គេចាប់ទៅដំណាលគ្នាមែន ឬយ៉ាងម៉េច?

ផាន ៖ ទេ ខ្ញុំអត់ដឹងទេ ។ បើដូចថាឈ្មោះ ឡូត សួយ ហ្នឹងគេដឹងច្បាស់លាស់ ព្រោះអីគេនៅជុំគ្នា បងជីដូនមួយគេហ្នឹងបានដឹង ហើយបើចាប់គេអត់ឲ្យឃើញទេ ។ គេហៅទៅប្រជុំទៅរៀន ។

សម្លេងអ្នកជិតខាង ៖ ហើយដឹងតែអង្គការហៅទៅប្រជុំពេលយប់ហើយ

ផាន ៖ ដឹងតែស្រេចហើយ ។

សម្លេងអ្នកជិតខាង ៖ កាលហ្នឹងវាបែកការណ៍ពួកនិរតីនិងពាយ័ព្យអីហ្នឹងណា ។

ប៊ុនថន ៖ អីចឹង រាល់ថ្ងៃមីងមានកូនប៉ុន្មាននាក់?

ផាន ៖ មានកូនប្រាំនាក់ ។

ប៊ុនថន ៖ គ្រួសាររបស់អ្នកមីងឈ្មោះអីវិញ?

ផាន ៖ ឈ្មោះប្រាំងសុល ។

ប៊ុនថន ៖ ហើយសព្វថ្ងៃគាត់ធ្វើអីដែរមីង?

ផាន ៖ សព្វថ្ងៃអត់ធ្វើអីតែ គិតតែដាំចង្ហាន់ឲ្យលោកនៅវត្ត ប្រគេនលោក បម្រើលោក នៅវត្ត

ប៊ុនថន ៖ បាទ! ហើយ អ្នកមីង ចង់សួរអ្នកមីងសំណួរចុងក្រោយ អ្នកមីងធ្លាប់លឺពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ផាន ៖ ទេ ខ្ញុំធ្លាប់លឺតែក្នុងទូរទស្សន៍មកដែរ ។

ប៊ុនថន ៖ ចុះមីងយល់យ៉ាងម៉េចដែរពីតុលាការហ្នឹងវិញ យល់ពីគំនិតខ្លួនឯង?

ផាន ៖ ខ្ញុំយល់ថា មកពីគិតខុស ។ គិតខុសមកពីគិតសម្លាប់ប្រជាជនច្រើនពេក ។

ប្រុញ ៖ ខាងខ្មែរក្រហមហ្នឹងអ្នកមីង?

ផាន ៖ ចាំ!

ប៊ុនថន ៖ ហើយអីចឹងមានយល់ឃើញយ៉ាងម៉េចទៀតទេ ដូចថា គិតថាខ្មែរក្រហមក៏ និយាយថាមានខ្វះល្អមានអីដែរ អ្នកមីង?

ផាន ៖ មាន មានអ្នកល្អមានអ្នកអាក្រក់អីចឹងឯង ។ មិនមែនអាក្រក់ទាំងអស់ទេ ។

ប៊ុនថន ៖ ប្រុញមានអីសួរគាត់ទៀតទេ?

ប្រុញ៖ អីចឹងមីងមានយល់ថារឿងខ្មែរក្រហមអី ពត៌មានអីគេបានចែកផ្សាយមកច្រើនដល់នេះទេ?

ផាន ៖ គេផ្សាយតើ ។

ប៊ុនថន ៖ មីងយល់ថាវាមានប្រយោជន៍អីយ៉ាងម៉េចដែរមីង?

ផាន ៖ អឹម!

ប៊ុនថន ៖ នេះគ្រាន់តែជាការគិតធម្មតាថាការដែលគេបង្កើតតុលាការនេះមានប្រយោជន៍អីដល់ប្រ-ជាជនដែលរស់នៅពល់ថ្ងៃ?

ផាន ៖ វាមានប្រយោជន៍ដែរ ដូចថាតុលាការកាត់ទោសរកអ្នកខុសរកអ្នកត្រូវ ។ នរណាខុសនរណាត្រូវ ។

ប្រុញ ៖ ដូចជាអត់មានអីទៀតទេ ។

ប៊ុនថន ៖ អីចឹងអ្នកមីង ខ្ញុំអរគុណអ្នកមីងហើយ ។

ផាន ៖ ចាំ!

«ចប់»